*Creation*

Copyright © 2012 by The Gospel Coalition

Published by Crossway
a publishing ministry of Good News Publishers
Wheaton, Illinois 60187, U.S.A.

This edition published by arrangement with Crossway.
All rights reserved.

This project was accomplished in partnership with The Gospel Coalition International Outreach.

# ការបង្កបង្កើត

លោក អេនឌ្រូ អែម ដាវីស Andrew M. Davis

## មាតិកា


លក្ខណៈ និងគោលបំណងនៃស្នាព្រះហស្ត.....2

ការគំរាមកំហែងរបស់ធម្មជាតិនិយម.....5

សប្តាហ៍បង្កបង្កើត លោកុប្បត្តិ ១.....7

ចំនុចខ្ពស់នៃការបង្កបង្កើត រូបភាពនៃព្រះ.....10

ការបង្កើតមនុស្សជាការបង្កើតពិសេស សេចក្តីលម្អិតនៃលោកុប្បត្តិ ២.....12

ព្រះបានបង្កើតមនុស្សដំបូងជាស្នាព្រះហស្តដែលមានជីវិត.....13

សេចក្តីបង្គាប់ពិសេសរបស់ព្រះ.....13

ការបង្កើតអេវ៉ា និងអាពាហ៍ពិពាហ៍.....14

ការធ្លាក់ចុះដែលវិនាសមួយចំពោះការបង្កបង្កើត.....15

ផែនដីថ្មីនិងស្ថានសួគ៌ថ្មី.....15

ការអនុវត្តដែលមកពីសេចក្តីពិតដែលថា ព្រះជាម្ចាស់បានបង្កើតរបស់សព្វសារពើ.....15

កំណត់.....17


ព្រះអាទិករ និងគ្រប់របស់សព្វសារពើដែលព្រះអង្គបានបង្កើតខុសគ្នាឆ្ងាយណាស់។ មានតែព្រះទេដែលមិនមានការចាប់ផ្តើម គឺទ្រង់គង់នៅដោយឯកឯង និងមិនពឹងផ្អែកលើអ្វីទាំងអស់ក្នុងការបន្តការគង់នៅរបស់ទ្រង់។ គ្រប់យ៉ាងទាំងអស់ទៀតត្រូវបង្កើតឡើងដោយព្រះ និងសំរាប់ព្រះ។ នៅក្នុងជំពូកនេះ យើងនឹងពិចារណាលើគោលលទ្ធិនៃការបង្កបង្កើត សារៈសំខាន់នៃការបង្កបង្កើត និងការអនុវត្តសេចក្តីពិតនោះនៅក្នុងជីវិតរបស់យើង។

## *លក្ខណៈ និងគោលបំណងនៃស្នាព្រះហស្ត*

គ្រប់ទាំងព័ត៌មានដែលយើងមានទាក់ទងនឹងការបង្កបង្កើតសកលលោកមកពីការបើកសំដែងពីព្រះ។ ប្រភពការដឹងពីរដ៏អស្ចារ្យ គឺសព្វសារពើដែលព្រះបានបង្កើតនៅជុំវិញយើង និងព្រះគម្ពីរ ដែលបរិយាយអំពីការបង្កបង្កើតយ៉ាងត្រឹមត្រូវសំរាប់យើង។ កាលដើមដំបូង ព្រះបានបង្កើតសកលលោកមួយដែលបើកសំដែងនូវការគង់នៅ និងលក្ខណៈពិតរបស់ទ្រង់ ដើម្បីឲ្យយើងនឹងស្គាល់ហើយថ្វាយបង្គំទ្រង់។ រ៉ូម ១:២០ និយាយថា "ដ្បិតអ្វីៗរបស់ទ្រង់ដែលរកមើលមិនឃើញតាំងពីកំណើតលោកិយមក ទោះទាំងព្រះអចេស្តាដ៏នៅអស់កល្បជានិច្ច និងនិស្ស័យជាព្រះរបស់ទ្រង់ នោះឃើញច្បាស់វិញ ដោយពិចារណាយល់របស់ទាំងប៉ុន្មានដែលទ្រង់បានបង្កើតមក"។

ព្រះបានបង្កើតសកលលោកដើម្បីបង្ហាញសិរីល្អរបស់ទ្រង់។ព្រះមិនបានបង្កើតវាដោយសារតែទ្រង់ខ្វះខាត និងត្រូវការអ្វីនោះទេ ប៉ុន្តែដោយសារសេចក្តីអស្ចារ្យរបស់ទ្រង់ ដែលទ្រង់ចង់ប្រទានឲ្យដោយសុទ្ធា។ នៅក្នុងកណ្ឌវិវរណៈមានពួកចាស់ទុំម្ភៃបួននាក់ដែលនៅជុំវិញបល្ល័ង្ក កំពុងបំពេញ សម្រេចគោលបំណងនៃរបស់ទាំងប៉ុន្មានដែលទ្រង់បានបង្កើត នៅពេលពួកគេសរសើរតម្កើងសិរីល្អរបស់ព្រះដោយព្រោះទ្រង់បានបង្កើតអ្វីៗទាំងអស់ "ឱព្រះអម្ចាស់ជាព្រះនៃយើងរាល់គ្នាអើយ ទ្រង់គួរនឹងទទួលសិរីល្អ កិត្តិនាម និងព្រះអរចេស្តា ដ្បិតទ្រង់បានបង្កើតរបស់សព្វសារពើមក ហើយគឺដោយបំណងព្រះហឫទ័យទ្រង់ហើយដែលរបស់ទាំងនោះបានកើតមក ហើយមាននៅផង" (វិវរណៈ ៤:១១)។

នៅពេលព្រះបានបង្កើតសកលលោក ទ្រង់បានចាក់សិរីល្អរបស់ទ្រង់ទៅក្នុងអាតូម និងប្រព័ន្ធសាំញ៉ាំនិមួយៗ ទាំងនៅក្នុងលោកធាតុ និងបរិស្ថាន។ ដូចទំនុកដំកើង ១៩:១ សរសេរថា "ផែនដីសំដែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញការដែលព្រះហស្តទ្រង់ធ្វើ"។ ការបង្កបង្កើតមិនកំពុងរង់ចាំដើម្បីបង្ហាញសិរីល្អរបស់ព្រះទេ គឺវាបង្ហាញរួចទៅហើយ។ សេរភីមហោះនៅជុំវិញបល្ល័ង្ករបស់ព្រះអម្ចាស់បន្លឺសំឡេងយ៉ាងខ្លាប់ខ្លួនថា "បរិសុទ្ធ បរិសុទ្ធ គឺព្រះយេហូវ៉ានៃពួកពលបរិវារទ្រង់បរិសុទ្ធ ផែនដីទាំងមូលមានពេញដោយសិរីល្អនៃទ្រង់!" (អេសាយ ៦:៣)។

## គោលបំណងរបស់មនុស្សជាតិ ការស្គាល់សិរីល្អរបស់ព្រះ

ទំនាយមួយរបស់ហាបាគុកប្រកាសអំពីគោលបំណងរបស់មនុស្សជាតិ (ហើយនិងប្រវត្តិសាស្ត្រប្រោសលោះ): "ដ្បិតមនុស្សនឹងស្គាល់ដល់សិរីល្អនៃព្រះយេហូវ៉ានៅពេញលើផែនដី ដូចជាទឹកក៏នៅពេញសមុទ្រដែរ" (ហាបាគុក ២:១៤)។ ដោយសារផែនដីបង្ហាញសិរីល្អរបស់ព្រះរួចហើយ នោះការមួយដែលត្រូវធ្វើគឺ ឲ្យផែនដីបានពេញ ដោយការស្គាល់ដល់សិរីល្អនោះ។ កាតព្វកិច្ចនេះមិនអាចត្រូវបានបំពេញដោយបរិយាកាសរបស់ផែនដី ដើមស៊ីដា ភ្នំហេមពាន្តខ្ពស់ត្រដែតរបស់ប្រទេសនេប៉ាល់ សត្វឥន្ទ្រីហើរខ្ពស់ ឬសត្វគោព្រៃដ៏ខ្លាំងបានទេ។ ទោះបើរបស់ដែលបានបង្កើតមកទាំងនេះបង្ហាញសិរីល្អរបស់ព្រះ ក៏ពួកគេមិនអាចស្គាល់សិរីល្អរបស់ព្រះបាន។ ការថ្វាយបង្គំនោះគឺជាកាតព្វកិច្ចរបស់មនុស្សជាតិដែលត្រូវបានបង្កើតក្នុងរូបភាពនៃព្រះដើម្បីស្រាវជ្រាវទាំងការបង្ហាញសិរីល្អរបស់ព្រះផ្ទាល់ និងលាក់កំបាំងនៅក្នុងគ្រប់ផ្នែកទាំងអស់នៃការបង្កបង្កើត។

ប៉ុន្តែសាកនាដកម្មធំធេងនៃការបះបោររបស់អ័ដាមនៅក្នុងសួនច្បារអេដែនគឺថា ចិត្តរបស់មនុស្សដែលគួរតែរីករាយនៅក្នុងព្រះដ៏ជាព្រះអាទិករ ដែលបានថ្វាយបង្គំរបស់ដែលកើតមកវិញ (រ៉ូម ១:២៥)។ ដូច្នេះ ទោះបីជាមនុស្សជាតិបានចំរើនមានគ្នាយ៉ាងច្រើនបំពេញផែនដីដោយរូបភាពនៃព្រះយ៉ាងណាក៏ដោយ ក៏គោលបំណងដើមរបស់ព្រះអម្ចាស់ (ផែនដីមួយដែលពេញដោយការស្គាល់ដល់សិរីល្អរបស់ទ្រង់) នៅតែរង់ចាំការបំពេញសំរេច។

មានតែកម្លាំងមួយប៉ុណ្ណោះនៅក្នុងសកលលោកដែលមានអំណាចផ្លាស់ប្រែចិត្តដែលថ្វាយបង្គំរូបព្រះរបស់មនុស្សឲ្យក្លាយទៅជាចិត្តដែលនឹងស្គាល់ដល់សិរីល្អរបស់ព្រះអម្ចាស់ដែលបានបង្ហាញនៅក្នុងការបង្កបង្កើតនោះ។ កម្លាំងនោះគឺជាដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។ ដោយសារដំណឹងល្អនេះ ចិត្តរឹងរបស់យើងត្រូវបានផ្លាស់ប្តូរដើម្បីអោយយើងនឹងឃើញសិរីល្អរបស់ព្រះចាំងជះមកជុំវិញយើងទាំងអស់គ្នា។ ការបំពេញសំរេចនៃសេចក្តីសន្យាដ៏សំខាន់នេះរង់ចាំផ្ទៃមេឃថ្មី និងផែនដីថ្មី នៅពេលសិរីល្អនៃព្រះនឹងបំភ្លឺរបស់ដែលកើតមកទាំងអស់ ហើយពួកសុចរិតផ្ទាល់នឹង "ភ្លឺដូចជាថ្ងៃនៅក្នុងនគររបស់ព្រះវរបិតានៃគេ" (ម៉ាថាយ ១៣:៤៣)។

## ការអប់រំអំពីការគង់នៅ និងលក្ខណៈសម្បត្តិរបស់ព្រះ

ការអប់រំរបស់យើងអំពីការគង់នៅ និងលក្ខណៈសម្បត្តិរបស់ព្រះ–បានចាប់ផ្តើមពីពេលដែលយើងនៅក្នុងផ្ទៃម្តាយរបស់យើង ហើយបានបន្តពីមួយថ្ងៃទៅ មួយថ្ងៃមុនពេលយើងបានរៀនចេះភាសា។ យើងត្រូវបានបង្រៀនដោយសំឡេងចង្វាក់បេះដូងរបស់ម្តាយរបស់យើង ការទទួលអារម្មណ៍កក់ក្តៅ រសជាតិនៅក្នុងមាត់របស់យើង ពន្លឺធ្វើឲ្យព្រិលភ្នែកនៅពេលកើត

មក ការមើលឃើញពណ៌ និងក្លិនក្រអូបនៃសំលៀកបំពាក់។ ក្នុងទំនុកដំកើង ២២:៩ ដាវីឌនិយាយថា "ប៉ុន្តែគឺទ្រង់ដែលធ្វើឲ្យទូលបង្គំចេញពីផ្ទៃម្តាយមក ទ្រង់បានឲ្យទូលបង្គំទុកចិត្ត ក្នុងកាលដែលនៅ បៅដោះម្តាយនៅឡើយ"។ នៅពេលដាវីឌនៅជាក្មេងបៅដោះ ព្រះបានបង្រៀនគាត់ពីរបៀបទុកចិត្តនៅពេលម្តាយរបស់គាត់បានបំពេញសេចក្តីត្រូវការខាងសាច់ឈាមរបស់គាត់។ ព្រះបានកំពុងរៀបចំដាវីឌឲ្យទុកចិត្តលើព្រះសំរាប់សេចក្តីសង្គ្រោះព្រលឹងរបស់គាត់។ ដូច្នេះ ការបង្កើតរូបកាយរៀបចំយើងសំរាប់សេចក្តីជំនឿដែលសង្គ្រោះ។

នៅពេលដែលយើងនៅក្មេងប្រហែលជាយើង ដើរកាត់សម្រស់របស់ព្រៃ ស្រូបយកក្លិនរបស់ព្រៃ ខ្យល់រំភើយនៅពេលល្ងាចប៉ះនឹងមុខ ស្ញើចសរសើរទេសភាពឆើតឆាយដូចជា ជ្រលងភ្នំល្អរំពៃមានដើមឈើចម្រុះពណ៌ នោះចិត្តរបស់យើងត្រូវបានផ្តុំឡើងសំរាប់សេចក្តីពិតសំខាន់របស់សកលលោក ព្រះដ៏មានអំណាចព្រះចេស្តា។

ចំណេះដឹងនេះកំពុងមាននៅជុំវិញពិភពលោក គឺមិនមែនតែជាតិសាសន៍មួយ ឬតំបន់មួយនៅលើផែនដីដែលទទួលចំណេះដឹងនេះទេ។ ទំនុកដំកើង ១៩:៣-៤ និយាយអំពីរបៀបដែលស្ថានសួគ៌កំពុងប្រកាសសិរីល្អរបស់ព្រះ "ឯពាក្យសំដី ឬភាសា នោះគ្មានលឺឡើយ គ្មានអ្នកណាដែលលឺសំឡេងនៃរបស់ទាំងនោះទេ ប៉ុន្តែដំណឹងដែលរបស់ទាំងនោះផ្សាយមកក៏បានចេញទៅគ្រប់ផែនដី ហើយសេចក្តីនោះបានលឺទៅដល់ទីបំផុតលោកិយ"។ របស់សព្វសារពើដែលព្រះបានបង្កើតបានអប់រំមនុស្សទាំងអស់នៅក្នុងពិភពលោកនេះអំពីការគង់នៅ និងលក្ខណៈសម្បត្តិរបស់ព្រះ។

## គ្រប់ទាំងអស់ត្រូវបានបង្កើតឡើងដោយព្រះគ្រីស្ទ និងសំរាប់ព្រះគ្រីស្ទ

គ្រប់ទាំងអស់នៅលើស្ថានសួគ៌ និងផែនដី ទោះមើលឃើញនិងមើលមិនឃើញក្តី ត្រូវបានបង្កើតឡើងដោយព្រះគ្រីស្ទ និងសំរាប់ព្រះគ្រីស្ទ

> គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានបង្កើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ (យ៉ូហាន ១:៣)
>
> ដែលទ្រង់ជារូបអង្គនៃព្រះដ៏មើលមិនឃើញ ជាបងច្បងនៃគ្រប់ទាំងអស់ដែលព្រះបានបង្កើតមក ដ្បិតគឺទ្រង់ហើយដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ នោះសុទ្ធតែកើតមកដោយសារទ្រង់ )ហើយសំរាប់ទ្រង់ទាំងអស់ផង (កូល៉ុស ១:១៥-១៦)
>
> នៅជាន់ក្រោយបង្អស់នេះ ទ្រង់បានមានបន្ទូលនឹងយើងរាល់គ្នា ដោយសារព្រះរាជបុត្រាវិញ ដែលទ្រង់បានតាំងឱ្យបានគ្រប់របស់ទាំងអស់ទុកជាមរដក ព្រមទាំងបង្កើតលោកិយ ដោយសារព្រះរាជបុត្រានោះដែរ (ហេព្រើរ ១:២)

នៅក្នុងរបៀបអាថ៌កំបាំងមួយព្រះបានមានបន្ទូលឲ្យសកលលោកកើតមានពីទទេ ហើយព្រះគ្រីស្ទគឺជាព្រះបន្ទូលដែលព្រះបានមានបន្ទូលបង្កើតដែលមានអំណាចនេះ(យ៉ូហាន ១:៣)។ សកលលោកត្រូវបានបង្កើតសំរាប់ព្រះគ្រីស្ទ (កូល៉ុស ១:១៦) ហើយព្រះបានតម្រូវឲ្យព្រះគ្រីស្ទធ្វើជា "អ្នកគ្រងរបស់ទាំងអស់ទុកជាមរតក" (ហេព្រើរ ១:២)។ ដូច្នេះ នៅក្នុងរបៀបប្លែកមួយ អាតូមនិមួយៗនៅក្នុងសកលលោកដែលមើលឃើញ និងអង្គភាពនីមួយនៅក្នុងអាណាចក្រខាងវិញ្ញាណជារបស់ព្រះគ្រីស្ទ។

គួរឲ្យស្ញើចសរសើរជាងនេះ ពីពេលមួយទៅពេលមួយសកលលោកដែលព្រះបានបង្កើត ពឹងផ្អែកលើព្រះគ្រីស្ទសំរាប់ដំណើរមាននៅរបស់វា "ទ្រង់ (ព្រះគ្រីស្ទ) គង់នៅមុនទាំងអស់ ហើយរបស់ទាំងអស់ក៏នៅស្ថិតស្ថេរដោយសារទ្រង់" (កូល៉ុស ១:១៧)។ ការនេះមានន័យថា សកលលោកនឹងឈប់មាននៅ ប្រសិនបើព្រះគ្រីស្ទមិនបានប្រើបំណងព្រះហឫទ័យដែលមានអំណាចរបស់ទ្រង់ក្នុងការរក្សាវាឲ្យមាននៅនោះ។ សេចក្តីពិតដែលថា មនុស្សមានសមត្ថភាពស្រាវជ្រាវ និងវិភាគសកលលោកដែលមើលឃើញ មិនបន្ថយអធិបតីភាពរបស់ព្រះទៅលើគ្រប់ផ្នែករបស់វានោះទេ។ អ្នកនិពន្ធ

ផ្សេងៗក្នុងព្រះគម្ពីរដឹងអំពីដំណើរចុះឡើងរបស់ទឹកតាមធម្មជាតិ ប៉ុន្តែពួកគេចូលចិត្តនិយាយថាព្រះបានបញ្ជូនទឹកភ្លៀង ពីព្រោះរបៀបនិយាយទាំងពីរនេះមិនប្រឆាំងគ្នានោះទេ។ សត្វស្លាបបានរបួសធ្លាក់ចុះមកដីដោយព្រោះកម្លាំងស្រូបនៃផែនដី (ភូវិពល) ប៉ុន្តែយោងទៅតាមព្រះយេស៊ូវ នោះគ្មានសត្វស្លាបណាដែលធ្លាក់ចុះមកលើដីដែលព្រះវរបិតានៃស្ថានសួគ៌របស់ទ្រង់មិនយល់ព្រមនោះឡើយ។

## *ការគំរាមកំហែងរបស់ធម្មជាតិនិយម*

នៅក្នុងការវិភាគចុងក្រោយ ការមាននៅរបស់សកលលោកមានការពន្យល់តែពីរប៉ុណ្ណោះគឺ វាត្រូវបានបង្កើតដោយព្រះ ឬចលនាវិវត្តន៍ដោយដំណើរដែលឥតមានអង្គណាធ្វើជាបុព្វហេតុឡើយ។ ប្រសិនបើទ្រឹស្តីវិវត្តន៍សន្មតថា គ្រប់ទាំងអស់បានកើតមកដោយដំណើរដែលឥតមានអង្គណាធ្វើជាបុព្វហេតុ នោះច្បាស់ហើយទ្រឹស្តីនោះត្រូវជាច់ដោយឡែកពីសេចក្តីពិតដែលថា ព្រះអាទិករបានបង្កើតរបស់សព្វសារពើ។ ប៉ុន្តែ ជួនកាលគេ**មិន**ប្រើពាក្យ "ទ្រឹស្តីវិវត្តន៍" ដោយសន្មតថា គ្រប់ទាំងអស់បានកើតមកដោយដំណើរដែលឥតមានអង្គណាធ្វើជាបុព្វហេតុ ហើយពីព្រោះគេបានប្រើពាក្យ"ទ្រឹស្តីវិវត្តន៍" ក្នុងន័យខុសៗគ្នា នោះធ្វើឲ្យរឿងនេះមានភាពស្មុគស្មាញ។

យោងតាមព្រះគម្ពីរ ព្រះមានបន្ទូលថាមនុស្សជាតិដែលមានបាប បើទោះត្រូវបានហ៊ុំព័ទ្ធដោយភស្តុតាងច្បាស់លាស់អំពីការគង់នៅ និងលក្ខណៈរបស់ព្រះដែលមើលមិនឃើញក៏ដោយ បង្ខាំងសេចក្តីពិតដោយព្រោះគេទុច្ចរិត (រ៉ូម ១:១៨)។ ម៉្យាងវិញទៀត យើងខិតខំបង្ខាំងសេចក្តីពិតមួយដែលយើងមិនចង់ទទួលយកគឺ មានព្រះអាទិករដែលបរិសុទ្ធ និងមានអំណាចលើទាំងអស់ ហើយយើងត្រូវទទួលខុសត្រូវចំពោះទ្រង់។ ពេលខ្លះអ្នកបដិសេធអាទិទេពទទួលស្គាល់ចំនុចនេះ។ លោក រីឆាត ដឃីន Richard Dawkins សរសេរថា "ជីវសាស្ត្រគឺជាការសិក្សាអំពីសត្វ និងរុក្ខជាតិដ៏ស្មុគស្មាញដែលផ្តល់រូបរាងដែលត្រូវបានបង្កើតសំរាប់គោលបំណងមួយ"។[២] ក្នុងន័យផ្សេងទៀត មនុស្សត្រូវតែ បង្ខាំងសេចក្តីពិតដែលថា គ្រប់របស់ទាំងអស់ត្រូវបានបង្កើតមកសំរាប់គោលបំណងមួយ!

វាមានតម្លៃដែលទាំងអ្នកវិទ្យាសាស្ត្រ និងអ្នកកាត់ស្រាយព្រះគម្ពីរមានការកាត់ស្រាយខុសៗគ្នាលើទិន្នន័យរបស់វិទ្យាសាស្ត្រ និងព្រះគម្ពីរ។ បន្ថែមលើការច្របូកច្របល់ មនុស្សខ្លះគឺទាំងអ្នកវិទ្យាសាស្ត្រ និងអ្នកកាត់ស្រាយបទគម្ពីរគ្រីស្ទបរិស័ទ ហើយ មនុស្សទាំងនេះមិនតែងតែយល់ស្របជាមួយអ្នកវិទ្យាសាស្ត្រ ឬអ្នកកាត់ស្រាយព្រះគម្ពីរផ្សេងៗទៀតទេ។

ឧទាហរណ៍ខ្លះអាចជួយបាន។ ទាក់ទងនឹងព្រះគម្ពីរ គ្រីស្ទបរិស័ទខ្លះជឿថា មានគម្លាតពេលវេលាមួយដែលមានប្រវែងគ្មានកំណត់មួយរវាងលោកុប្បត្តិ ១:១ និង១:២ អ្នកខ្លះជឿថាថ្ងៃនិមួយៗនៅក្នុងលោកុប្បត្តិ ១ តំណាងឲ្យសម័យកាលមួយ អ្នកខ្លះជឿថាផែនដីនៅក្មេង (ថ្ងៃនិមួយៗនៅក្នុងលោកុប្បត្តិ១គឺជាថ្ងៃដែលមានម្ភៃបួនម៉ោង ហើយការបង្កបង្កើតបានកើតឡើងមិនលើសពីមួយម៉ឺនឆ្នាំកន្លងទៅនោះទេ) អ្នកខ្លះជឿថាលោកុប្បត្តិ ១គឺជា សប្តាហ៍អក្សរសាស្ត្រមួយ (ថ្ងៃនិមួយៗគឺជាថ្ងៃដែលមានម្ភៃបួនម៉ោង ប៉ុន្តែសប្តាហ៍ទាំងមូលត្រូវជាការបង្កបង្កើតអក្សរសាស្ត្រដែលមិនមានបំណងប្រាប់យើងឲ្យច្បាស់លាស់នូវ "អ្វីដែលបានកើតឡើង" ប៉ុន្តែមានបំណងរៀបជាលំដាប់បញ្ជី ប្រយោជន៍ដើម្បីអោយសេចក្តីពិតអំពីព្រះជាម្ចាស់ និងសព្វសារពើដែលព្រះបានបង្កើតដោយប្រើនិមិត្តរូប។ មានសេចក្តីជំនឿខុសៗគ្នាទាក់ទងនឹង ទេវសាស្ត្រទាំងនេះ)។

ការកាត់ស្រាយខ្លះនៃលោកុប្បត្តិ ១ អាចស៊ីគ្នាជាមួយនឹងទស្សនៈដែលថាព្រះបានបង្កើតរបស់សព្វសារពើហើយទ្រង់គង់នៅគ្រប់គ្រងលើដំណើរការការវិវត្តន៍ទាំងអស់។ មានទស្សនៈផ្សេងៗគ្នានៅក្នុងទស្សនៈខាងលើនេះ។ ទស្សនៈមួយថាព្រះបង្កើតគ្រប់ទាំងអស់ហើយគ្រប់គ្រងការវិវត្តន៍ទាំងស្រុងហើយការវិវត្តន៍បានដំណើរយ៉ាងយឺតៗរហូត។ ប៉ុន្តែមានទស្សនៈមួយទៀតថា ព្រះបង្កើតគ្រប់ទាំងអស់ហើយគ្រប់គ្រងការវិវត្តន៍ទាំងស្រុង តែមានពេលជាក់លាក់មួយចំនួនដែលព្រះបានអន្តរាគមន៍យ៉ាងអស្ចារ្យដើម្បីធ្វើឲ្យការវិវត្តន៍បានដំណើរការយ៉ាងឆាប់រហ័ស ដូច្នេះនឹងមានអន្តរ ចរន្តថ្មីៗបានបង្កើតមួយរំពេចដូចជាឲ្យមនុស្ស មានខ្លឹមសារខុសគ្នាពីសត្វស្វា។ ព្រះបានបង្កើតមនុស្សជាតិឲ្យមានគុណភាពខុសស្នាព្រះហស្តដទៃទៀត គឺមនុស្សជាតិជាអ្នកទទួលរូបភាពនៃទ្រង់ហើយត្រូវទុកបម្រុងសំរាប់ជីវិតអស់កល្ប។

គ្រីស្ទបរិស័ទជាច្រើនគិតថាទស្សនៈមួយឬច្រើនជាងនៃទស្សនៈទាំងនេះថាមិនអាចទទួលយកបានទេ ហើយពួកគេយល់ស្របតែទស្សនៈមួយឬពីរប៉ុណ្ណោះ។ ជាឧទាហរណ៍ ជារឿយៗមានការពិភាក្សាថា មិនមានហេតុផលតាមព្រះគម្ពីរឲ្យយើងមើលឃើញរយៈពេលរាប់រយ កោដិឆ្នាំនៅក្នុងលោកុប្បត្តិ ១នោះទេ។ ហេតុផលផ្សេងៗដែលគ្រីស្ទបរិស័ទខ្លះផ្លាស់ប្តូរការកាត់ស្រាយរបស់ពួកគេលើលោកុប្បត្តិ ១ មកពីខាងក្រៅព្រះគម្ពីរ អ្នកភូមិសាស្រ្តនិងអ្នកវិទ្យាសាស្រ្តដទៃទៀតប្រាប់យើងថា មានភស្តុតាងច្រើនសន្ធឹកដែលថាផែនដីមានអាយុរាប់រយកោដិឆ្នាំ។

ដោយសារតែការពិភាក្សាទាំងនេះ មានគ្រីស្ទបរិស័ទខ្លះកាត់ស្រាយលោកុប្បត្តិ១ឡើងវិញដើម្បីឲ្យត្រូវគ្នានឹងទ្រឹស្តីវិទ្យាសាស្រ្តដែលគេជឿភាគច្រើន។ បើសិនយើងអត់មានទ្រឹស្តីវិទ្យាសាស្រ្តទាំងនោះទេ នោះយើងនឹងមិនរកឃើញការកាត់ស្រាយលោកុប្បត្តិ ១ បែបនោះទេ។ អ្នកខ្លះនិយាយថា ការកាត់ស្រាយឡើងវិញនេះធ្វើឲ្យខូចអត្ថន័យច្បាស់លាស់របស់ព្រះគម្ពីរ។ ទោះយ៉ាងណា បញ្ហាមានភាពស្មុគស្មាញ។ តាំងពីយូរណាស់មកហើយគឺមុនវិទ្យាសាស្រ្តសម័យទំនើបទៅទៀត អូហ្គាស្ទីន Augustine (សតវត្សទីបួន) បាននិយាយថា ការកាត់ស្រាយលោកុប្បត្តិ១មានការពិបាក ប៉ុន្តែគាត់បានបង្រៀន (សំរាប់អ្វីដែលគាត់បានគិតថាជាហេតុផលតាមទេវ សាស្រ្ត និងព្រះគម្ពីរដែលបង្គាប់) ថាសកលលោកត្រូវបានបង្កើតមកភ្លាម ហើយការបង្កបង្កើតនៅក្នុងលោកុប្បត្តិ១ គឺជាការបង្កបង្កើតអក្សរសាស្រ្តដែលមាននិមិត្តសញ្ញាជាច្រើន ដើម្បីធ្វើលំដាប់នៃគំនិតខាងទេវ សាស្រ្ត រួមទាំងការផ្តល់ឲ្យមានលំដាប់នៅក្នុងសប្តាហ៍របស់មនុស្ស ហើយនិងការបង្កើតថ្ងៃសប្ប័ទ។ ដូច្នេះ គឺនៅមុនវិទ្យាសាស្រ្តសម័យទំនើប មានទ្រឹស្តីហើយដែលថា លោកុប្បត្តិ១មាននិមិត្តសញ្ញា។

សមាជិករបស់ក្រុមចំរុះដំណឹងល្អ (The Gospel Coalition) មិនមានទស្សនៈដូចគ្នាទាក់ទងនឹងសេចក្តីលំអិតទាំងអស់នោះទេ ប៉ុន្តែយើងទាំងអស់គ្នាជឿយ៉ាងមុតមាំថា មានតែព្រះមួយអង្គទេដែលទ្រង់គង់ស្ថិតស្ថេរអស់កល្បជានិច្ច ទ្រង់គឺជាព្រះអាទិករនៃរបស់សព្វសារពើ ទ្រង់បានបង្កើតរបស់សព្វសារពើល្អប្រពៃ អ័ដាម និងអេវ៉ាគឺជាតួអង្គមនុស្សជាតិពិតក្នុងប្រវត្តិសាស្រ្តដែលបាននាំឲ្យមានមនុស្សជាតិ ហើយថាបញ្ហាគ្រឹះដែលយើងប្រឈមបានកើតឡើងដោយសារការថ្វាយបង្គំរូបព្រះ និងការបះបោររបស់មនុស្ស ហើយនិងបណ្តាសាដែលមានតាមក្រោយ។ ហេតុផលសំរាប់ការប្រកាន់ថា សេចក្តីពិតនេះមិនអាចបោះចោលបានឡើយ គឺជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយនឹងបទគម្ពីរជាច្រើននៅក្នុងព្រះគម្ពីរ មិនគ្រាន់តែជំពូកចាប់ផ្តើមរបស់លោកុប្បត្តិនោះទេ។ ជាឧទាហរណ៍ ប៉ុលប្រាប់យើងថាព្រះ "បានបង្កើតមនុស្សគ្រប់សាសន៍ពីឈាមតែមួយឲ្យបាននៅពេញលើផែនដី" (កិច្ចការ ១៧:២៦)។

នៅក្នុងវិទ្យាសាស្រ្តក៏(ដូចជាក្នុងការកាត់ស្រាយព្រះគម្ពីរដែរ) មានភាពមិនច្បាស់លាស់និងទស្សនៈផ្សេងគ្នាច្រើនជាងអ្វីដែលគេបានទទួលស្គាល់ដែរ។ ទោះបើចំនួនភាគច្រើនរបស់អ្នកវិទ្យាសាស្រ្តកាន់តាមទ្រឹស្តី (Big bang) (ទ្រឹស្តីវិទ្យាសាស្រ្តដែលជឿថា សកលលោកបានកើតមកពីធាតុទាំងអស់ដែលរួញរួមជាដុំមួយតូចរឹង ហើយពេលមួយវាបានផ្ទុះឡើងប្រហែលជា១៥,000,000,000 ឆ្នាំមុន បង្កើតជាសកលលោកតែម្តង) ចំនួនភាគតិចនៃអ្នកវិទ្យាសាស្រ្តមិនជឿថាទ្រឹស្តីនេះត្រឹមត្រូវនោះទេ។ សំខាន់ជាងនេះទៅទៀត គ្មានទ្រឹស្តីដែលគេទទួលស្គាល់យ៉ាងទូលំទូលាយអំពីទំរង់ដែលមានទំងន់ធ្ងន់ដែលមិនគួរឲ្យជឿបានកើតមានជាលើកដំបូងនោះទេ។ ទ្រឹស្តីមួយសន្មតថា សកលលោករីក និងរួម ប៉ុន្តែមិនមានមនុស្សច្រើនគាំទ្រទ្រឹស្តីនេះទេ។

ប្រសិនបើយើងមិនព្រួយបារម្ភអំពីសំនួរផ្សេងៗអំពីរបៀបដែលទំរង់ដែលមានទំងន់ធ្ងន់បានកើតមាន ហើយផ្តោតលើភពផែនដី នោះយើងឃើញថាទ្រឹស្តីផ្សេងៗដែលទាក់ទងនឹងការអភិវឌ្ឍន៍នៃជីវិតតាមរយៈការវិវត្តន៍មានការកែប្រែជាបន្តបន្ទាប់។ កំណត់ត្រាហ្វូស៊ីលរក្សាទុកចន្លោះ (ចន្លោះនៃដំណើរការវិវត្តន៍នៃរបស់ទាំងអស់ដែលមានការវិវត្តន៍បន្តិចម្តងៗរហូតមកដល់ទំរង់បច្ចុប្បន្ន) ជាច្រើននៅក្នុងលំដាប់របស់ចន្លោះនៃការផ្លាស់ប្តូរ ដូច្នេះឥឡូវនេះមនុស្សច្រើនជឿតាមទស្សនៈរបស់អ្នកទ្រឹស្តីការវិវត្តន៍នៅហាវីត Harvard គឺលោក ស្ទេផាន ជេ ហ្គោល Stephen Jay Gould។ គាត់ជឿថា ការវិវត្តន៍មិនតែងតែមានការអភិវឌ្ឍន៍បន្តិចម្តងៗរហូតទៅនោះទេ ប៉ុន្តែវាមានការផ្លាស់ប្តូរនិមួយៗក្នុងពេលមួយរំពេច។ លើស

ពីនេះ ថ្វីបើមានការខិតខំស្រាវជ្រាវយ៉ាងណាក៏ដោយ ប្រសិនបើយើងសន្មតថាមិនមានព្រះទេ គឺមានតែធាតុប៉ុណ្ណោះ នោះផ្លូវពីធាតុគ្មានសរីរាង្គទៅដល់កោសិកាដែលមានសមត្ថភាពបង្កើតកោសិកាទៀតនៅតែមានភាពមិនច្បាស់លាស់។

ការពិភាក្សាថ្មីៗនេះអំពីការរចនាបង្កើតដោយភាពប៊ិនប្រសព្វ (Intelligent design) ក៏មានភាពស្មុគស្មាញផងដែរ។ ក្នុងពីរទសវត្សមុន អ្នកវិទ្យាសាស្ត្រ និងទស្សនៈវិទូមួយក្រុមតូចបានពិភាក្សាថា រចនាសម្ព័ន្ធជីវសាស្ត្រជាច្រើនមាន "ផ្នែកជាច្រើនដែលជាប់ទាក់ទងគ្នាហើយមិនអាចដកចេញពីគ្នាបាន"។ រចនាសម្ព័ន្ធបែបដូចនេះធ្វើការនិងត្រូវបានទ្រទ្រង់ (ដូចជាភ្នែក) ត្រូវការការអភិវឌ្ឍន៍ការវិវត្តន៍ផ្នែកជាច្រើនដែលចាប់ផ្តើមក្នុងពេលតែមួយ ដូច្នេះភាពទំនងឈានមកដល់សូន្យ។ សមាសភាពរបស់រចនាសម្ព័ន្ធមិនអាចបានអភិវឌ្ឍន៍មួយចំណែកម្នាក់ដោយព្រោះពួកវាមានតួនាទីសំខាន់ផ្សេងពីទីតាំង និងតួនាទីរបស់ពួកវានៅក្នុងរចនាសម្ព័ន្ធទាំងមូល។ ពួកគេជឿថានេះគឺជាភស្តុតាងសំរាប់ការរចនាបង្កើតដែលមានភាពប៊ិនប្រសព្វ។

អ្នកវិទ្យាសាស្ត្រភាគច្រើនឆ្លើយតបថា ទ្រឹស្តីនេះដូចជាទ្រឹស្តី "ព្រះនៃគម្លាត" (God of the gaps) ដែលថា នៅពេលណាវិទ្យាសាស្ត្រមិនអាចពន្យល់ការអ្វីមួយបាន នោះយើងយកព្រះមកពន្យល់វិញ (យើងនិយាយថាព្រះបានធ្វើការនោះ) ប៉ុន្តែលទ្ធផលអាក្រក់ពីទ្រឹស្តីនេះគឺថា នៅពេលវិទ្យាសាស្ត្រពន្យល់កាន់តែច្រើនជាង នោះព្រះត្រឡប់កាន់តែតូចទៅៗវិញ (មនុស្សមិនត្រូវការព្រះធ្វើជាការពន្យល់ ព្រោះគេមិនចាំបាច់និយាយថាព្រះជាអ្នកដែលបានបង្កើតព្រឹត្តិការណ៍នោះទេ)។ អស់អ្នកដែលជឿតាមទស្សនៈការរចនាបង្កើតដែលមានភាពប៊ិនប្រសព្វ (Intelligent design) ទទូចថា អ្វីដែលពួកគេកំពុងពិភាក្សាគឺខុសគ្នាពីទស្សនៈព្រះនៃគម្លាត យើងពិតជាយល់អំពីការទាក់ទងយ៉ាងសំខាន់អំពីរចនាសម្ព័ន្ធទាំងនេះហើយនិងភស្តុតាងពីរចនាសម្ព័ន្ធទាំងនេះ និងពីវិទ្យាសាស្ត្រផ្ទាល់ គឺថាយើងត្រូវតែរួមបញ្ចូលទស្សនៈការរចនាបង្កើតដែលមានភាពប៊ិនប្រសព្វទៅក្នុងការពន្យល់។

វាកាន់តែមានភាពច្បាស់លាស់ថា នៅពីក្រោយការពិភាក្សានេះគឺជាជម្លោះគ្រឹះអំពីវិទ្យាសាស្ត្រ។ ភាគីមួយគិតថា វិទ្យាសាស្ត្រគឺជាក្រុមវិន័យ ទ្រឹស្តីដែលអាចសាកល្បងបាន ទំរង់ការនិងការវាស់ស្ទង់ដែលអាចធ្វើឡើងវិញបាន ដែលជួយឲ្យយើងអាចកាន់តែយល់អំពីសកលលោក។ អស់អ្នកដែលប្រឆាំងនឹងទស្សនៈការរចនាបង្កើតដែលមានភាពប៊ិនប្រសព្វគិតថា វិទ្យាសាស្ត្រគឺជាក្រុមវិន័យ ទ្រឹស្តីដែលអាចសាកល្បងបាន ទំរង់ការនិងការវាស់ស្ទង់ដែលអាចធ្វើឡើងវិញបានដែលជួយឲ្យយើងអាចកាន់តែយល់អំពីសកលលោក ដោយស្រាវជ្រាវតែធាតុប៉ុណ្ណោះ ប៉ុន្តែ ក៏លើសពីនេះគេសន្មតថា វិធីសាស្ត្របែបនេះមិនអាចនិយាយអំពីការមាននៅនៃរបស់អ្វីមួយ ឬអ្នកណាម្នាក់ដែលនៅខាងក្រៅទំរង់ខាងសំភារៈបាននោះឡើយ។

ក្នុងន័យផ្សេងទៀត ទស្សនៈវិទ្យាសាស្ត្រនេះជឿថា ព្រះនិងវិទ្យាសាស្ត្រមិនទាក់ទងគ្នាសោះ។ នេះមិនមានន័យថាគ្មានព្រះទេ គឺអាចមានព្រះឬអត់មានព្រះ។ ប៉ុន្តែវិទ្យាសាស្ត្រមិនអាចនិយាយថា មានព្រះឬក៏អត់នោះទេ។ នៅពេលយើងព្យាយាមឈ្វេងយល់អំពីសកលលោក យើងមិនពឹងផ្អែកលើព្រះសោះ តែយើងអាចពឹងផ្អែកលើសមត្ថភាពស្រាវជ្រាវរបស់យើង។

ការពិត អ្នកវិទ្យាសាស្ត្រជាច្រើន សូម្បីតែអ្នកបដិសេធអាទិទេពក៏មានការស្ងើចសរសើរ នៅពេលពួកគេមើលទៅសកលលោក រូបកាយ កោសិកា និងសរីរាង្គរបស់មនុស្ស ហើយឃើញសោភ័ណភាពនៃរបស់ទាំងនោះ។

ការឆ្លុះបញ្ចាំងទាំងនេះត្រៀមរៀបចំយើងសំរាប់ការអានដែលផ្តោតលើអត្ថបទព្រះគម្ពីរ។

## *សប្តាហ៍បង្កបង្កើត លោកុប្បត្តិ ១*

សេចក្តីថ្លែងដំបូងគេនៅក្នុងព្រះគម្ពីរគឺជាគ្រឹះសំរាប់របស់សព្វសារពើដែលមានតាមក្រោយ "កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី" (លោកុប្បត្តិ ១:១)។ យ៉ាងហោចណាស់ សេចក្តីថ្លែងនេះបង្រៀនអំពីសេចក្តីពិតសំខាន់បី

១. ព្រះគង់នៅមុនសកលលោក។ ព្រះបានគង់នៅពេលដើមដំបូង ហើយបានធ្វើសកម្មភាពបង្កើតអ្វីៗផ្សេងទៀតឲ្យមានឡើង។

២. សកលលោកបានមានការចាប់ផ្ដើម។ វាមិននៅជាអស់កល្បនោះទេ (ដូចដែលអ្នកវិទ្យាសាស្ត្រខ្លះបង្រៀន) ឬវិលជុំ (ដូចជាសាសនាភាគខាងកើតបង្រៀន)។

៣. ព្រះបានបង្កើតរបស់សព្វសារពើដោយផ្ទាល់នៅក្នុងសកលលោក។ គ្មានអ្វីបានកើតឡើងដោយគ្រាន់តែកម្លាំងធម្មជាតិប៉ុណ្ណោះ ដូចដែលពួកអ្នកបដិសេធអាទិទេពដែលជឿតាមទ្រឹស្ដីវិវត្តន៍បង្រៀននោះទេ។

សេចក្ដីពិតដែលថា ព្រះជាម្ចាស់បានបង្កើតរបស់សព្វសារពើគឺជាមូលដ្ឋានគ្រឹះសំរាប់សេចក្ដីពិតទាំងអស់ដែលមានតាមក្រោយ ហើយប្រវត្តិសាស្ត្របានប្រោសលោះពឹងផ្អែកលើសេចក្ដីពិតនេះ។ "ឯផែនដីបានខូច ហើយនៅទទេ មានសុទ្ធតែងងឹតនៅគ្របលើជម្រៅទឹក" (លោកុប្បត្តិ ១:២)។ សកលលោកត្រូវការការងាររបន្តរបស់ព្រះក្នុងការនាំវាមកដល់សណ្ដាប់ធ្នាប់និងសោភ័ណភាពដ៏ពេញលេញ។ សេចក្ដីពិតដែលថា "ព្រះវិញ្ញាណរបស់ព្រះក៏រេរានៅពីលើទឹក" ផ្ដល់នូវការយល់ច្បាស់ដំបូងអំពីតួនាទីប្រទានជីវិតរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលជាតួនាទីដែលត្រូវបានបន្តពន្យល់ពេញនៅក្នុងព្រះគម្ពីរ។

បន្ទាប់មកព្រះបានមានបន្ទូលប្រកបដោយអធិបតីភាព "ចូរឲ្យមានពន្លឺឡើង ដូច្នេះពន្លឺក៏មានឡើង" (លោកុប្បត្តិ ១:៣)។ នៅទីនេះយើងត្រូវបានណែនាំអំពីកម្លាំងនិងអំណាចរបស់ព្រះនៅក្នុងសកលលោក គឺជាព្រះបន្ទូលដែលមានអំណាចរបស់ទ្រង់។ ព្រះបង្កើតនិងគ្រប់គ្រងស្នាព្រះហស្តរបស់ទ្រង់ដោយព្រះបន្ទូល។ "ផ្ទៃមេឃបានកើតមកដោយសារព្រះបន្ទូលព្រះយេហូវ៉ា ហើយពួកពលបរិវារនៅលើនោះបានកើតដោយសារខ្យល់ពីព្រះឱស្ឋទ្រង់" (ទំនុកដំកើង ៣៣:៦)។ បន្ទាប់មកព្រះរៀបចំចង្វាក់នៃជីវិតនៅលើផែនដីនៅក្នុងដំណើរវិលចុះឡើងដែលទ្រង់ហៅថា "ថ្ងៃ" និង "យប់" : "នោះក៏មានល្ងាចមានព្រឹកឡើង ជាថ្ងៃទីមួយ" (លោកុប្បត្តិ ១:៥)។ ចង្វាក់នៃល្ងាចនិងព្រឹកនិងការរាប់ចំនួនថ្ងៃពេញក្នុងលោកុប្បត្តិ ១ បានបង្កើតគំរូមួយសំរាប់ពេលវេលាដែលមនុស្សស្គាល់។

ការសង្កត់ធ្ងន់មួយនៃការពិភាក្សាសហសម័យទាក់ទងនឹងការកាត់ស្រាយលើលោកុប្បត្តិ ១ គឺជាអត្ថន័យរបស់ពាក្យ "ថ្ងៃ"។ ដោយសារពាក្យភាសាហេព្រើរ yōm (ថ្ងៃ) អាចសំដៅ លើកំឡុងពេលវេលាដ៏យូរ ដូចជាយុគសម័យរបស់ប្រវត្តិសាស្ត្រ។ តាមអត្ថន័យយ៉ាងសាមញ្ញបំផុតពាក្យ"ថ្ងៃ"មានន័យថាកំឡុងម្ភៃបួនម៉ោង ឬជាកំឡុងពេលរបស់ពន្លឺព្រះអាទិត្យគឺផ្ទុយនឹងពេលងងឹត ("ថ្ងៃនិងយប់")។ ជាការពិតចង្វាក់ដែលនិយាយឡើងវិញនៅក្នុងលោកុប្បត្តិ ១ "នោះក៏មានល្ងាចមានព្រឹកឡើងជាថ្ងៃទីមួយ (ទីពីរ ទីបី...ល)" ពិភាក្សាគាំទ្រថ្ងៃដែលមានម្ភៃបួនម៉ោងធម្មតា។ ការយល់បែបនេះត្រូវបានបទគម្ពីរមួយផ្សេងទៀតអះអាងថាត្រឹមត្រូវ "ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ាទ្រង់បានធ្វើផ្ទៃមេឃផែនដី ហើយនឹងសមុទ្រ ព្រមទាំងរបស់សព្វសារពើនៅស្ថានទាំងនោះដែរ រួចដល់ថ្ងៃទី ៧ ទ្រង់ឈប់សំរាក ហេតុនោះបានជាទ្រង់បានប្រទានពរដល់ថ្ងៃឈប់សំរាក ហើយក៏ញែកចេញជាបរិសុទ្ធ" (និក្ខមនំ ២០:១១)។ ការពិត យើងក៏ត្រូវតែទទួលស្គាល់ថា ប្រសិនបើទ្រឹស្ដីដែលផ្ទុកដោយនិមិត្តសញ្ញាជាច្រើនរបស់អូហ្គាស្ទីន Augustine ត្រូវបានគេប្រើ ឬទ្រឹស្ដីដែលស្រដៀងគ្នានៅសហសម័យនេះ ថ្ងៃទាំងនេះនៅក្នុងលោកុប្បត្តិ១ប្រហែលជាកំឡុងពេលម្ភៃបួនម៉ោងជាផ្នែកនៃរចនាសម្ព័ន្ធអក្សរសាស្ត្រដែលកំពុងតែកាត់ស្រាយការបង្កើត។

អ្វីដែលច្បាស់លាស់នោះគឺថា មានគោលការណ៍មួយនៅក្នុងបីថ្ងៃដំបូងនៃការបង្កបង្កើត ពន្លឺ*ញែក*ពីភាពងងឹត ទឹកខាងលើ*ញែក*ពីទឹកខាងក្រោម និងសមុទ្រ*ញែក*ពីដីគោក។ ព្រះបានបង្កើតព្រំដែនមិនស្ថិតស្ថេររវាងរលកសមុទ្រដែលមានកម្លាំងខ្លាំង និងដីគោក។ យើងអាចឃើញសេចក្ដីដូចគ្នានេះនៅក្នុងការបើកសំដែងអង្គទ្រង់ទៅកាន់យ៉ូប

> តើអ្នកណាបានបិទទ្វារសមុទ្រទុក នៅក្នុងកាលដែលធ្លាយចេញមក បែបដូចជាសំរាលចេញពី ផ្ទៃម្ដាយ គឺក្នុងកាលដែលអញបានបាំងដោយពពក ទុកដូចជាអាវ យើងរុំព័ទ្ធនឹងសេចក្ដីងងឹតយ៉ាងក្រាស់ ទុកជាកន្សែង ព្រមទាំងដាក់

គោលចារិកឲ្យ ហើយដាក់រនុកនិងទ្វារផង ដោយពាក្យថា ឯងនឹងមកបានតែត្រឹមនេះនឹងទៅទៀតមិនបាន រលកដ៏អង់អាចរបស់ឯងត្រូវឈប់នៅទីនេះ។ (យ៉ូប ៣៨:៨-១១)

នៅពេលព្រះបានបង្កើតដីគោក ទ្រង់អាចបង្កើតជីវិតអស្ចារ្យឲ្យរស់នៅលើដី។ ទ្រង់បានមានបន្ទូល នោះក៏មានជីវិតរុក្ខជាតិនៅលើផែនដី ជារុក្ខជាតិមានគ្រាប់តាមពូជ។ ពាក្យ គ្រាប់ និងតាមពូជ និយាយអំពីប្រភេទរុក្ខជាតិទាំងឡាយនិងសមត្ថភាពបង្កើតឡើងវិញនិងដុះរីកពេញផ្ទៃផែនដី។ តើអ្នកណាមិនអាចមើលឃើញប្រភេទរុក្ខជាតិផ្សេងៗនៅលើផែនដី? ព្រះបានមានបន្ទូលបង្កើតដើមឈើដ៏ធំ និងខ្លាំងនិងមាំមួន ផ្កាមានក្លិនក្រអូប ហើយនិងផ្កាព្រៃល្អរំពៃ។ ព្រះបានបង្កើតរបស់មានជីវិតនិងរបស់រីកដុះដើម្បីលំអដីគោកជាមួយប្រព័ន្ធជីវសាស្ត្រដែលស្មុគស្មាញ រុក្ខជាតិដែលស្រូបយកជីជាតិចេញពីដី កាបូនឌីអុកស៊ីតចេញពីខ្យល់ ហើយនិងថាមពលពីព្រះអាទិត្យដើម្បីរស់នៅ និងរីកធំធាត់ហើយផ្គត់ផ្គង់ចំណីអាហារសំរាប់សត្វពាហនៈ និងមនុស្សដែលនឹងមានតាមក្រោយ។

នៅថ្ងៃទីបួននៃការបង្កបង្កើត ព្រះបានចាប់ផ្តើមពង្រីកសិរីល្អរបស់ទ្រង់ពេញលើសកលលោក។ ទោះបើទ្រង់បានបង្កើតពន្លឺនៅដើមដំបូង នោះឥឡូវទ្រង់សព្វព្រះទ័យផ្ទេរឲ្យ ព្រះអាទិត្យ ព្រះ ច័ន្ទ និងផ្កាយ ដែលព្រះអង្គបានបង្កើតទទួលភារកិច្ចផ្តល់ពន្លឺមកកាន់ផែនដី។ ពន្លឺសព្វថ្ងៃមកពីព្រះអាទិត្យ និងផ្កាយផ្សេងៗ ប៉ុន្តែក្នុងដំណើររឿងក្នុងលោកុប្បត្តិ ទាំងនេះត្រូវបានបន្ថែមតាមក្រោយទេ។ ព្រះអាទិត្យគឺជាស្នាព្រះហស្តមួយដែលគួរឲ្យឆ្ងល់ កម្លាំងភ្លើងឆេះក្តៅដែលបង្ហាញចំពោះមនុស្សជាតិដែលក្រអឺតក្រទមអំពីប្រាជ្ញានិងអធិបតីភាពដ៏ជ្រាលជ្រៅ របស់ព្រះអង្គដែលគ្មានអ្នកណាអាចពិពណ៌នាបានទេ។

គ្មានអ្វីដែលមនុស្សជាតិអាចធ្វើចំពោះព្រះអាទិត្យបានទេ ទោះការល្អឬការអាក្រក់។ យើងមិនអាចធ្វើឲ្យវាភ្លឺជាងឬងងឹតជាង ធំជាងឬតូចជាង ជិតជាងឬឆ្ងាយជាង ក្តៅជាងឬត្រជាក់ជាងបាននោះទេ។ ប្រសិនបើមនុស្សទាំងអស់បានសម្រេចចិត្តថា យើងចង់បំផ្លាញព្រះអាទិត្យ នោះនឹងគ្មានអ្វីដែលយើងអាចធ្វើចំពោះវាបានឡើយ។ ប្រសិនបើយើងបានប្រើអាវុធបរមាណូទាំងអស់របស់យើងហើយបញ្ជូនពួកវាជារ៉ុកកែតទៅផ្ទុះនៅលើផ្ទៃខាងក្រៅព្រះអាទិត្យ នោះរ៉ុកកែតទាំងនោះនឹងមិនទៅដល់ព្រះអាទិត្យទេ ប៉ុន្តែនឹងត្រូវឆេះរលាយរាប់លានគីឡូម៉ែត្រពីព្រះអាទិត្យវិញ។ ថ្មីៗនេះ NASA កំពុងដាក់គម្រោងបេសកកម្មស្រាវជ្រាវដែលនឹងអាចទៅដល់ផ្ទៃខាងក្រៅព្រះអាទិត្យចំងាយតែ៥.៦ លានគីឡូម៉ែត្រប៉ុណ្ណោះ។

ព្រះអាទិត្យឆេះពីមួយថ្ងៃទៅមួយថ្ងៃដោយមិនអាចដឹងការថយចុះថាមពលរបស់វាទេ វាភ្លឺខ្លាំងណាស់ដែលយើងនឹងងងឹតភ្នែកបើយើងសំឡឹងមើលវាយូរ។ ព្រះអាទិត្យផ្តល់សិរីល្អដល់ព្រះដោយសារថាមពល និងពន្លឺចំឡែករបស់វា ហើយព្រះបានបង្កើតព្រះអាទិត្យសំរាប់មនុស្សជាតិ បញ្ចេញពន្លឺនៅលើមេឃ "បញ្ចេញពន្លឺមកលើផែនដី"(លោកុប្បត្តិ ១:១៧)។

ព្រះក៏បានបង្កើតពន្លឺព្រះច័ន្ទសំរាប់មនុស្សនៅលើផែនដីផងដែរ ប៉ុន្តែពន្លឺដែលពន្លឺព្រះច័ន្ទបញ្ចេញទៅលើផែនដីគឺខុសពីពន្លឺដែលព្រះអាទិត្យបញ្ចេញមកលើផែនដី។ ពន្លឺព្រះច័ន្ទជះត្រឡប់ពន្លឺរបស់ព្រះអាទិត្យទៅកាន់ផែនដី ដូចក្នុងគំនិតពាក្យប្រៀបដែលយើងជាគ្រីស្ទបរិស័ទថ្ងៃមួយនឹងបញ្ចេញពន្លឺរបស់ព្រះគ្រីស្ទនៅលើស្ថានសួគ៌ដែរ។ លោកុប្បត្តិ ១:១៦ ថ្លែងថា "ទ្រង់ក៏ធ្វើឲ្យមានផ្កាយទាំងប៉ុន្មានដែរ"។ ភាពរីកចម្រើនខាងលោកធាតុវិទ្យាក្នុងពេលថ្មីៗនេះ ដូចជាកែវយឺតហាបិល Hubble Space telescope ដែលវិលជុំវិញផែនដី និងបញ្ជូនមកផែនដីវិញនូវរូបភាពចំឡែករបស់ផ្កាយ បានបង្ហាញប្រាប់យើងថា សកលលោកដែលព្រះបានបង្កើតគឺមានទំហំធំមហិមា។

នៅថ្ងៃទីប្រាំ ព្រះបានបង្កើតមច្ឆាជាតិ និងបក្សីជាតិ។ ប្រភេទមច្ឆាជាតិ និងបក្សីផ្សេងៗដែលរាប់មិនអស់ធ្វើឲ្យយើងកោតសរសើរ និងថ្វាយសិរីល្អដល់ព្រះ។ ព្រះបានបង្កើតត្រីបាឡែនជាសត្វធំជាងគេដែលមានជីវិតនៅលើផែនដី ហើយបន្ទាប់មកព្រះបើកព្រះហស្តរបស់ទ្រង់ដើម្បីចិញ្ចឹមវាដោយធារាសុខុមប្រាណ១១៨០គីឡូក្រាមជារៀងរាល់ថ្ងៃ។ មានត្រីយ៉ាងស្អាតអស្ចារ្យនៅតំបន់ត្រូពិកដែលមានរចនាបង្កើតយ៉ាងរស់រវើកមានច្រើនពណ៌។ ត្រីចំឡែក (brotulids) ដែលអាចរស់នៅក្នុងជម្រៅស្ទើរតែប្រាំបីគីឡូម៉ែត្រពីផ្ទៃខាងលើសមុទ្រ។ សត្វបក្សីក៏បង្ហាញអំពីដំណើរច្នៃប្រឌិតរបស់ព្រះផងដែរ

ពីព្រោះពួកវាខ្លះដូចជាសត្វឥន្ទ្រីហើរសំកាំងខ្ពស់ពីខ្យល់អាកាសកក់ក្ដៅដោយមិនងាយទទះស្លាបរបស់ពួកវាឡើយ ហើយខ្លះទៀតដូចជាសត្វបក្សីម៉្យាងដែលទទះស្លាបរបស់ពួកវាច្រើនដល់ប៉ែតសិបដងក្នុងមួយវិនាទី។ សត្វស្ទាំងផិរិគ្រិន (Peregrine) គឺជាសត្វដែលធ្វើដំណើរលឿនបំផុតដែលអាចធ្វើដំណើរឆ្ងាយរហូតដល់៣៨៩គីឡូម៉ែត្រក្នុងមួយម៉ោងដោយការហើរបញ្ឈរ។

ព្រះបានប្រទានពរដល់មច្ឆាជាតិ និងបក្សីជាតិ ហើយបង្គាប់ពួកវាឲ្យចម្រើនឡើងនៅក្នុងសមុទ្រ និងអាកាស។

នៅថ្ងៃទីប្រាំមួយ ព្រះបានបំពេញដីគោក និងបង្កើតចតុប្បាទជាតិនៅលើផែនដី សត្វស្រុក សត្វព្រៃ សត្វលូនវារ។ ភាពស្មុគស្មាញ និងប្រភេទសត្វផ្សេងៗទាំងនេះ គឺជាទីបន្ទាល់ច្បាស់លាស់អំពីប្រាជ្ញា និងសេចក្ដីល្អរបស់ព្រះ។ សត្វខ្លះមានអំណាច និងមានកម្លាំងខ្លាំង ដូចជាសត្វដំរីដែលអាចលើកទំងន់២៧០គីឡូក្រាមបានដោយប្រមោយរបស់វា។ សត្វខ្លះមូរមុខហើយតូច ដូចជាសត្វស្កា(Rock Badger) ដែលរស់នៅទីចោទភ្នំហើយជញ្ជក់សំណើមពីកវកាប្បដែលដុះនៅលើច្រាំងថ្មចោទ។ ព្រះបានបង្កើតសត្វតោដែលមានអំណាចឲ្យគ្រហឹម សត្វភេឲ្យចេះហែលទឹក ដំរីទឹកឲ្យគ្រប់គ្រងទន្លេអាហ្វ្រិក ហើយនិងខ្លារខិនឲ្យរត់បានយ៉ាងលឿន។

## *ចំនុចខ្ពស់នៃការបង្កបង្កើត រូបភាពនៃព្រះ*

ដែលបានបំពេញដំណាក់កាលរុងរឿងដែលជាសកលលោកទាំងមូលដែលពេញដោយការផ្គត់ផ្គង់ដោយសេចក្ដីស្រលាញ់របស់ព្រះ នោះព្រះបានមកដល់ពេលវេលាសំរាប់ចំនុចខ្ពស់នៃការបង្កបង្កើត ការបង្កើតមនុស្សជាតិ ជាប្រុសជាស្រីក្នុងរូបភាពនៃព្រះ

> ទ្រង់ក៏មានបន្ទូលថា ចូរយើងធ្វើមនុស្សឱ្យដូចជារូបយើង ឱ្យមានភាពដូចយើង ហើយឱ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាសនិងសត្វជើង៤ដែលនៅលើផែនដីទាំងមូលព្រមទាំងសត្វលូនវារដែលវារនៅផែនដីផង ទ្រង់ក៏បង្កើតមនុស្សឱ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឱ្យចំនឹងរូប អង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី (លោកុប្បត្តិ ១:២៦-២៧)

មនុស្សជាតិខុសប្លែកពីគេពីព្រោះព្រះបានបង្កើតពួកគេនៅក្នុងរូបភាពនៃទ្រង់។ មនុស្សជាតិមិនត្រូវបានបង្កើតមកឲ្យធ្វើជាព្រះនោះទេ ប៉ុន្តែឲ្យដូចជារូបភាពនៃព្រះ។ តើ "រូបភាព" នេះមានផ្ទុកអ្វីខ្លះ? យ៉ាងហោចណាស់មានរបៀបសំខាន់ពីរដែលមនុស្សជារូបភាពនៃព្រះ។ (១) ក្នុងលក្ខណៈរបស់យើង។ យើងដូចជាព្រះនៅក្នុងសមត្ថភាពជាក់លាក់ (សមត្ថភាពគិត ផ្តល់ហេតុផល ធ្វើគម្រោង ស្រលាញ់ ជ្រើសរើស ប្រាថ្នា ទំនាក់ទំនង...ល) និងលក្ខណៈសម្បត្តិ (សេចក្ដីសុចរិត សេចក្ដីបរិសុទ្ធ សេចក្ដីមេត្តាករុណា សេចក្ដីអាណិតអាសូរ ប្រាជ្ញា...ល)។ (២) តួនាទីរបស់យើងនៅលើផែនដី។ ព្រះបានបង្កើតមនុស្សជាតិឲ្យធ្វើជាអ្នកគ្រប់គ្រងផែនដី (លោកុប្បត្តិ ១:២៦, ២៨)។

ការបង្កបង្កើតរបស់ព្រះក៏បង្កើតគំរូសំរាប់ភេទផងដែរ។ ព្រះបានបង្កើតមនុស្សជាប្រុសជាស្រី ម្នាក់ៗស្មើគ្នានៅក្នុងរូបភាពនៃទ្រង់ ប៉ុន្តែមានតួនាទី និងការផ្តោតខុសគ្នា គឺទាំងអស់តាមបែបផែនរបស់ព្រះ។ ការយល់ច្រឡំអំពីការស្រលាញ់ភេទដូចគ្នា និងទំរង់ភេទផ្សេងៗទៀតធ្វើឲ្យភាពខុសគ្នារវាងភេទប្រុស និងភេទស្រីមានភាពស្រពេចស្រពិល។ ព្រះបានសព្វព្រះទ័យឲ្យភាពខុសគ្នានៃភេទជាការល្អតាំងពីដើមដំបូង គឺវាជាការល្អណាស់ដែលបុរសធ្វើជាបុរស និងស្ត្រីធ្វើជាស្ត្រី។

ព្រះបានសព្វព្រះទ័យឲ្យមនុស្សជាតិចម្រើនកូនចៅជាច្រើនហើយមានពាសពេញផែនដីដោយរូបភាពនៃព្រះ ហើយថាការចម្រើនឡើងនេះជាលទ្ធផលនៃព្រះពរដែលព្រះអង្គប្រទានអោយ។ នៅពេលព្រះប្រទានពរដល់មនុស្សប្រុស និងមនុស្សស្រី (ដែលយើងហៅពួកគេនៅក្នុងលោកុប្បត្តិ ២ ថាប្តីនិងប្រពន្ធ) នោះកូនចៅត្រូវបានបង្កើតហើយរូបភាពនៃព្រះរីកផ្សាយ។ ដូច្នេះ កូនចៅគឺជាព្រះពរពីព្រះ មិនមែនបណ្តាសាដែលថ្លៃហើយមិនស្រណុកស្រួលដែលមនុស្សអាត្មានិយមខ្លះនៅក្នុងសង្គមរបស់យើងគិតនោះទេ។

ការផ្គត់ផ្គង់ដោយក្តីស្រលាញ់របស់ព្រះសំរាប់មនុស្សជាតិនិងសត្វចតុបាតទាំងអស់ត្រូវបានប្រកាសនៅចុងបញ្ចប់នៃដំណើររឿងបង្កបង្កើត គឺរុក្ខជាតិនិងដើមឈើមានគ្រាប់និងមានផ្លែតាមពូជសំរាប់មនុស្ស ហើយតិណជាតិបៃតងសំរាប់សត្វចតុបាត។ ការនេះបង្កើតនូវការផ្គត់ផ្គង់យ៉ាងប្រពៃ និងមានអំណាចមួយសំរាប់ជីវិតដែលកំពុងកើតមាន។ ដូចជាយើងបានលើកឡើងហើយថា ព្រះបានបង្កើតសកលលោកមួយដែលពឹងផ្អែកលើទ្រង់ ហើយព្រះទទួលបានសិរីល្អនៅក្នុងការពឹងផ្អែករបស់ស្នាព្រះហស្តនោះ។ សេចក្តីល្អរបស់ព្រះក្នុងការផ្គត់ផ្គង់អាហារ គឺជាផ្ទៃរឿងក្នុងការសញ្ជឹងគិតរបស់អ្នកនិពន្ធក្នុងទំនុកដំកើង ១០៤ "គ្រប់សត្វទាំងនោះសង្ឃឹមចាំតែទ្រង់ ឲ្យទ្រង់បានប្រទានចំណីដល់វាតាមត្រូវពេល ទ្រង់ក៏ប្រទានឲ្យហើយវាទទួលយក កាលទ្រង់លាព្រះហស្តទៅ នោះវាបានឆ្អែតដោយរបស់ល្អ" (ខ. ២៧-២៨)។

## សេចក្តីល្អរបស់ព្រះនៅក្នុងសេចក្តីល្អនៃការបង្កបង្កើត

ព្រះបញ្ចប់ដំណើររឿងការបង្កបង្កើតសកលលោករបស់ទ្រង់ដោយការប៉ាន់ប្រមាណ "រួចព្រះទ្រង់ទតគ្រប់ទាំងរបស់ដែលទ្រង់បានធ្វើនោះ ក៏ឃើញថា ទាំងអស់ជាការល្អប្រពៃ" (លោកុប្បត្តិ ១:៣១)។ នេះគឺជាការប្រកាសដ៏សំខាន់ ពីព្រោះនេះបង្រៀនថា របស់សព្វសារពើដែលព្រះបានបង្កើតមានខ្លឹមសារល្អ។ ពួកអ្នកទស្សនៈវិទូជនជាតិក្រិកនិងអ្នកខ្លះដែលតាមសាសនាខាងកើតបានបដិសេធសេចក្តីល្អរបស់ពិភពលោកដែលមើលឃើញ និងជាពិសេសរូបកាយរបស់មនុស្ស។ ព្រះបានប្រកាសថា គ្រប់ទាំងអស់ដែលទ្រង់បានធ្វើគឺល្អ។ ទោះយ៉ាងណា អ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺថា ការបង្កបង្កើតបានបង្ហាញថាព្រះអង្គទ្រង់ផ្ទាល់ល្អ។

យើងរស់នៅក្នុងសកលលោកមួយដែលត្រូវបានបង្កើតឡើងដោយសេចក្តីស្រលាញ់ និងប្រាជ្ញារបស់ព្រះដែលទ្រង់ល្អនិងស្រលាញ់អ្វីដែលទ្រង់បានបង្កើតមក។ យើងរស់នៅក្នុងភពមួយដែលត្រូវបានរៀបចំយ៉ាងពិសេសសំរាប់ជីវិតមនុស្សជាតិ។ ផែនដីធ្វើដំណើរវិលជុំវិញព្រះអាទិត្យក្នុងល្បឿន ១០៧០០០គីឡូម៉ែត្រក្នុងមួយម៉ោង។ ល្បឿននេះគឺពិតជាអ្វីដែលត្រូវការក្នុងទូទាត់កំលាំងស្រូបទាញរបស់ព្រះអាទិត្យហើយរក្សាផែនដីឲ្យមានចំងាយត្រឹមត្រូវពីព្រះអាទិត្យដើម្បីឲ្យជីវិតអាចចំរើនលូតលាស់បាន។ សេចក្តីល្អរបស់ព្រះកំណត់ជ្រុងនៃដំណើរទ្រេតរបស់អ័ក្សផែនដី២៣.៥ ដឺក្រេដែលកៀកនឹងព្រះអាទិត្យដើម្បីផ្តល់ឲ្យមានរដូវផ្សេងៗ។ ប្រសិនបើដំណើរទ្រេតបានបង្កើនដល់២៥ដឺក្រេ នោះរដូវក្តៅនឹងកាន់តែក្តៅខ្លាំង ហើយរដូវរងាកាន់តែត្រជាក់ខ្លាំង ដែលជាលទ្ធផលគឺជាការបំភ្លេចបំផ្លាញជីវិតរុក្ខជាតិនៅលើផែនដី។ ដូច្នេះ ល្បឿននិងទីតាំងរបស់ផែនដីគឺ "ល្អប្រពៃ" សំរាប់ជីវិតមនុស្ស។ ព្រះក៏បានកែតម្រូវបរិយាកាសផែនដីបានយ៉ាងល្អមិនដូចជាបរិយាកាសផ្សេងៗទៀតនៅក្នុងប្រព័ន្ធសុរិយគតិនោះឡើយ។ ឆ្ងាយពីលើក្បាលរបស់យើង អូហ្សូនបាំងវិទ្យុសកម្មពីព្រះអាទិត្យដែលអាចបណ្តាលឲ្យយើងកើតជំងឺដំបៅមហារីកបាន។ បរិយាកាសដែលការពារផែនដីពីអាកាសបាតុភូត ឆេះកំដៅឡើងខ្លាំងដល់ ៧០០០០តោននៃសំណល់អវកាសក្នុងមួយឆ្នាំ។ បរិយាកាសផ្ទុកអាហ្សូត៧៨ភាគរយនិងអុកស៊ីហ្សែន២១ភាគរយ ដែលល្អឥតខ្ចោះសំរាប់ជីវិត។ បើគ្មានអុកស៊ីហ្សែនទេនោះជីវិតដែលកំរើកទាំងអស់នឹងមិនអាចរស់នៅបានឡើយ ប៉ុន្តែបើចំនួនអុកស៊ីហ្សែនកើនឡើងដូចជា២៥ភាគរយ ភ្លើងនឹងឆេះឡើងយ៉ាងគំហុកភ្លាមៗនៅពាសពេញលើផែនដីហើយវាស្ទើរតែមិនអាចនឹងពន្លត់វាបានឡើយ។ អាហ្សូតមិនគ្រាន់តែពង្រាវអុកស៊ីហ្សែនប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់ជាជីសំខាន់សំរាប់ជីវិតរុក្ខជាតិផងដែរ។ យ៉ាងអស្ចារ្យក្នុងកំឡុងព្យុះអគ្គិសនីនៅពេញលើផែនដី ផ្លេកបន្ទោររួមបញ្ចូលអាហ្សូតនិងអុកស៊ីហ្សែនទៅក្នុងសមាសធាតុដែលសំខាន់សំរាប់ជីវិតរុក្ខជាតិ ហើយបន្ទាប់មក ភ្លៀងនាំសមាសធាតុទាំងនេះចូលទៅក្នុងដី។ ដូច្នេះហើយបរិយាកាសគឺ "ល្អប្រពៃ" សំរាប់ជីវិតរបស់មនុស្ស។

នៅមុនមរណៈភាពរបស់តារាវិទូលោក នីកូឡស ខូភឺនិខឹស Nicolaus Copernicus បានបោះពុម្ពសៀវភៅរបស់គាត់ដែលមានចំណងជើងថា *ការវិលរបស់ដែនអាកាស (On the Revolution of Celestial Spheres)*។ គាត់បានសរសេរថាព្រះអាទិត្យជាចំនុចកណ្តាលរបស់ប្រព័ន្ធសុរិយគតិ មិនមែនជាផែនដីទេ។ វិទ្យាសាស្ត្របានបង្ហាញថា ទស្សនៈរបស់គាត់គឺត្រឹមត្រូវ ប៉ុន្តែលោកុប្បត្តិ១នៅតែបង្រៀនថាផែនដីគឺជាចំនុចកណ្តាលនៃគោលបំណងរបស់ព្រះសំរាប់

សកលលោក។ នេះគឺជាសេចក្ដីពិតគោលដែលមិនអាចត្រូវជំទាស់បានឡើយ។ យោងតាមលោកុប្បត្តិ ១:១៤-១៨ ហេតុផលនានាដែលព្រះបានបង្កើតព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយគឺជាហេតុផលដែលយកផែនដីជាចំនុចកណ្ដាល ដើម្បីផ្ដល់ពន្លឺដល់ផែនដី ដើម្បីញែកថ្ងៃចេញពីយប់ ដើម្បីកំណត់រដូវកាល ថ្ងៃ និងឆ្នាំ។ កណ្ឌគម្ពីរវិវរណៈក៏បង្ហាញអំពីទស្សនៈវិស័យដែលយកផែនដីជាចំនុចកណ្ដាលផងដែរនៅពេលមានព្រឹត្តិការណ៍នៅលើផែនដីនិងក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ឈានមកចំនុចខ្ពស់ ផ្កាយធ្លាក់ពីលើមេឃដូចជាផ្លែល្វាជ្រុះធ្លាក់ពីដើមល្វា (វិវរណៈ ៦:១៣)។ ផែនដីគឺជាចំនុចកណ្ដាលនៃផែនការរបស់ព្រះសំរាប់សកលលោក។

### ការឈប់សំរាកនៅថ្ងៃសប្បទ

ដំណើររឿងនៃការបង្កបង្កើតរយៈពេលប្រាំពីរថ្ងៃនៅក្នុងលោកុប្បត្តិបញ្ចប់ដោយការដែលព្រះយកថ្ងៃសប្បទរបស់ទ្រង់ធ្វើជាការសំរាក ហើយបង្កើតថ្ងៃសប្បទជាថ្ងៃបរិសុទ្ធនិងមានពរ (លោកុប្បត្តិ ២:១-៣)។ ការពិត យើងមិនដែលយល់ថាព្រះបានសំរាកថ្ងៃសប្បទរបស់ទ្រង់ដោយព្រោះការងារបង្កបង្កើតសកលលោករបស់ទ្រង់ បានធ្វើឲ្យទ្រង់អស់កម្លាំងហើយទ្រង់ត្រូវការសំរាកបំពេញកម្លាំងរបស់ទ្រង់វិញនោះទេ។ អេសាយ ៤០:២៨ បញ្ជាក់ការនេះយ៉ាងច្បាស់ថា "ព្រះដ៏គង់នៅអស់កល្បជានិច្ច គឺព្រះយេហូវ៉ាជាព្រះដែលបានបង្កើតផែនដី ...ទ្រង់មិនដែលល្ងើយឡើយ ក៏មិនដែលអស់កំលាំងផង"។ ព្រះមិនបានឈប់ផ្គត់ផ្គង់និងទ្រទ្រង់សកលលោកដែលទ្រង់បានបង្កើតនោះទេ គឺព្រះបានបង្កើតសកលលោកដែលពឹងផ្អែកដល់ទ្រង់គ្រប់ពេលវេលាសំរាប់ការមាននៅរបស់វា។ ការសំរាកថ្ងៃសប្បទរបស់ព្រះមានពីរយ៉ាង (១) ការបង្ហាញសិទ្ធិដែលមានអំណាចរបស់ទ្រង់ក្នុងការគ្រប់គ្រងសកលលោក ដូចជាស្ដេចមួយអង្គយាងកាត់បន្ទប់បល្ល័ង្កដែលឡើងកំពូលបល្ល័ង្កងាកហើយបែរទៅរកដំណាក់របស់ទ្រង់ ហើយគង់នៅលើបល្ល័ង្កដឹកនាំ (២) ការបង្ហាញអំពីសេចក្ដីមេត្តាករុណារបស់ទ្រង់ចំពោះមនុស្សជាតិ ផ្ដល់ឲ្យពួកគេមានឱកាសចូលទៅក្នុងការសំរាករបស់ទ្រង់នៅក្នុងសម័យបច្ចុប្បន្ននេះ គឺមួយថ្ងៃក្នុងមួយសប្ដាហ៍ ហើយអស់កល្បនៅក្នុងស្ថានសួគ៌តាមរយៈសេចក្ដីជំនឿនៅក្នុងព្រះគ្រីស្ទផងដែរ (ហេព្រើរ ៤:១:១១)។

## *ការបង្កើតមនុស្សជាការបង្កើតពិសេស សេចក្ដីលម្អិតនៃលោកុប្បត្តិ ២*

អ្នកធ្វើអត្ថាធិប្បាយខ្លះបានមានការលំបាកក្នុងការយល់នូវដំណើររឿងនៃការបង្កបង្កើតខុសៗគ្នាដែលមាននៅក្នុងលោកុប្បត្តិ១និង២។ ទោះយ៉ាងណា ដូចដែលលោក ឆាល ស្ពឺជិន Charles Spurgeon បាននិយាយ(អំពីបញ្ហាខុសគ្នាខាងទេវសាស្ត្រ)ថា "ខ្ញុំមិនដែលព្យាយាមផ្សះផ្សារមិត្តភ័ក្តិនោះទេ!" លោកុប្បត្តិ១ផ្ដល់នូវដំណើររឿងនៃការបង្កបង្កើតសកលលោករបស់ព្រះដ៏ល្អ ហើយជាពិសេសគោលបំណងរបស់ទ្រង់ក្នុងការបង្កើតមនុស្សជាប្រុសជាស្រីក្នុងរូបភាពនៃទ្រង់។ ប៉ុន្តែលោកុប្បត្តិ២ផ្ដោតលើការបង្កើតមនុស្សប្រុសនិងមនុស្សស្រីដំបូងហើយនិងគោលបំណងរបស់ទ្រង់សំរាប់ពួកគេរៀងៗខ្លួនជាមួយសេចក្ដីលម្អិតដែលយើងត្រូវការ ចាំបាច់។ លោកុប្បត្តិ១និង២គឺដូចជាផែនទីរបស់ប្រទេសកម្ពុជាដែលមានផែនទីរបស់រាជធានីភ្នំពេញភ្ជាប់ជាមួយនៅលើទំព័រតែមួយ។

### ផែនដីដែលពឹងអាស្រ័យនិងមានសិរីល្អរង់ចាំអ្នកថែរក្សានិងអ្នកគ្រប់គ្រងរបស់ខ្លួន

លោកុប្បត្តិ២ពណ៌នាអំពីផែនដីមួយដែលបង្ហាញអំពីសិរីល្អរបស់ព្រះ ប៉ុន្តែមានការពឹងអាស្រ័យនិងកំពុងរង់ចាំអ្នកថែរក្សានិងអ្នកគ្រប់គ្រង។ បើទោះមានការប្រកាសថាផែនដីគឺ "ល្អប្រពៃ" នៅក្នុងលោកុប្បត្តិ១ក៏ដោយ ក៏មិនមានន័យថាផែនដីមិនអាចត្រូវបានអភិវឌ្ឍ និងធ្វើឲ្យប្រសើរឡើងបាននោះដែរ។ ដូច្នេះ លោកុប្បត្តិ ២:៥ និយាយអំពីពពួករុក្ខជាតិដែលត្រូវការការធ្វើកសិកម្មរបស់មនុស្សដើម្បីឈានដល់សក្ដានុពលពេញលេញរបស់ខ្លួន។ តើមនុស្សដំបូងនឹងបានជំនាញបែបនេះពីណាមក? វានឹងបានមកពីការបង្ហាត់បង្រៀនមកពីព្រះវរបិតានៃស្ថានសួគ៌របស់គាត់ គឺព្រះបានមានព្រះហឫទ័យ

ហ្វឹកហ្វឺនពូជពង្សរបស់ទ្រង់គឺអ័ដាមឲ្យចេះថែរក្សាផែនដី។ បទគម្ពីរគួរឲ្យកត់សម្គាល់មួយនៅក្នុងអេសាយ ២៨បង្ហាញទ្រង់បង្ហាត់បង្រៀនឱ្យមនុស្សមានគំនិតយល់ ហើយក៏បង្ហាញឱ្យគេចេះធ្វើដី

ឯអ្នកដែលភ្ជួររាស់ដើម្បីសាបព្រោះតើគេនៅតែភ្ជួរជានិច្ច តើគេចេះ តែបំបែកដី ហើយរាស់ស្រែរបស់ខ្លួនជាងរាបកាលណាគេបាន ពង្រាបដីហើយ នោះតើមិនព្រោះល្ងស ហើយបាចល្ងខ្មៅ ព្រមទាំងរោយស្រូវអោជ្ជសាលីទៅជាជួរៗ ហើយស្រូវឱកនៅកន្លែងដែលបានតំរូវទុក នឹងស្រូវអេប៉ូតតាមក្បែរភ្លឺផងទេឬអី ដ្បិតព្រះនៃគេទ្រង់បង្ហាត់បង្រៀនឱ្យគេមានគំនិតយល់ ហើយក៏បង្ហាញឱ្យចេះធ្វើ ពីព្រោះឯល្ងស នោះមិនត្រូវវាយដោយប្រដាប់មុតទេ ក៏មិនត្រូវឱ្យកង់រទេះកិនល្ងខ្មៅដែរ គឺត្រូវគោះល្ងសដោយរំពាត់ ហើយល្ងខ្មៅដោយដំបង ឯស្រូវសំរាប់ធ្វើនំបុ័ង នោះគេបញ្ជាន់វិញ ពីព្រោះគេមិនចង់វាយប្រឡេះជាងរាបទេ គឺគេបញ្ជាន់ដោយកង់រទេះ ដោយសេះវិញ ដំរិះនេះក៏មកពីព្រះយេហូវ៉ានៃពួកពលបរិវារ ដែលទ្រង់ប្រឹក្សាយ៉ាងអស្ចារ្យ ហើយមានប្រាជ្ញាយ៉ាងវិសេសផង។ (អេសាយ ២៨:២៤-២៩)

## *ព្រះបានបង្កើតមនុស្សដំបូងជាស្នាព្រះហស្តដែលមានជីវិត*

លោកុប្បត្តិ ២:៧ និទានអំពីការបង្កើតមនុស្សដំបូងពីធូលីដី "ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង"។ ខ្ញុំនៅចាំការទស្សនាការតាំងពិពណ៌នានៅក្នុងសារមន្ទីរវិទ្យាសាស្ត្របូស្តុន Boston ដែលបានគូរវាសដោយមនុស្សម្នាក់ ហើយពីខាងក្នុងគូរវាសនោះគឺជាដបជាតិគីមីដែលមានទំហំផ្សេងៗគ្នានសមាសភាគរឹង។ វាតំណាងឲ្យរូបកាយរបស់មនុស្សដែលត្រូវបានយកទឹកទាំងអស់ចេញ (រូបកាយរបស់មនុស្ស៦០ភាគរយគឺជាទឹក) ហើយអ្វីដែលនៅសល់គឺជាសមាសភាគនិងខនិជដែលអាចត្រូវបានគេជីកយកពីដីមក! មនុស្សដំបូងកើតមកពីដី (១កូរិនថូស ១៥:១៧) ហើយបន្ទាប់ពីការធ្លាក់ចុះទៅក្នុងអំពើបាប ព្រះបានប្រាប់អ័ដាមថាគាត់នឹងស្លាប់ហើយត្រឡប់ទៅជាដីវិញ "ពីព្រោះអញបានយកឯងពីដីមក ដ្បិតឯងជាធូលីដី ក៏ត្រូវត្រឡប់ទៅជាធូលីដីវិញ" (លោកុប្បត្តិ ៣:១៩)។

ទោះយ៉ាងណា ទោះបើយើងកើតមកពីធូលីដីក៏ដោយ ក៏យើងគួរតែងឿងឆ្ងល់ក្នុងសញ្ជឹងគិតលើភាពសាំញ៉ាំនៃរាងកាយរបស់មនុស្សដែលព្រះសូនបែបយ៉ាងអស្ចារ្យពីសមាសភាគផ្សេងៗនៅក្នុងផែនដីផងដែរ (ទំនុកដំកើង ១៣៩:១៤)។ យើងដឹងថាមាន DNA នៅក្នុងកោសិការាប់លានលាននៅក្នុងមនុស្សម្នាក់ ដែលប្រសិនមិនជំពាក់វាក់ឱនពីតួស្លឹកត្រចៀកទាំងពីរដែលមានក្នុងកោសិកានិមួយៗហើយបានបន្លាយពីដើមដល់ចុង នោះនឹងមានចំងាយពី១៦ទៅ៣២ពាន់លានគីឡូម៉ែត្រ។ តើគួរឲ្យអស្ចារ្យជាងអម្បាលម៉ានទៅទៀតចំពោះខួរក្បាលរបស់មនុស្សដែលព្រះបានបង្កើតមកដែលមានកោសិកាកាយប្បសាទមួយរយពាន់លាន (១០០,០០០,០០០,០០០) (ប្រមាណជាចំនួនដើមឈើក្នុងព្រៃអាម៉ាហ្សូនឯនោះ)?

## *សេចក្តីបង្គាប់ពិសេសរបស់ព្រះ*

ទោះបើព្រះបានរចនាពិភពលោកទាំងមូលពេញដោយសិរីល្អរបស់ទ្រង់ក៏ដោយ ក៏ព្រះអម្ចាស់បានរៀបចំកន្លែងមួយជាពិសេសសំរាប់អ័ដាម និងប្រពន្ធរបស់គាត់ឲ្យចាប់ផ្តើមដំណើររំភើបចិត្តនៃការរុករកនិងការអភិវឌ្ឍ ផងដែរ។ សួនច្បារនោះ "នៅស្រុកអេដែនទិសខាងកើត" (លោកុប្បត្តិ ២:៨) ហើយទ្រង់បានដាក់មនុស្សដែលទ្រង់បានបង្កើតនៅទីនោះ។ ព្រះបានផ្គត់ផ្គង់សួនច្បារអេដែនសំបូរទៅដោយដើមឈើមានផ្លែគ្រប់ប្រភេទ ដែលមើលទៅល្អស្អាតនិងចង់បរិភោគ។ នៅកណ្តាល

សួនច្បារអេដែនមានដើមឈើជីវិត។ ដើមដឹងខុសត្រូវក៏នៅក្នុងសួនច្បារនោះដែរ។ ដើមឈើទាំងនេះគឺជាសេចក្តីផ្តោតនៃសេចក្តីបង្គាប់ពិសេសដែលព្រះបានប្រទានឲ្យអ័ដាម។

លោកុប្បត្តិ ២:១០-១៤ ពណ៌នាអំពីទន្លេបួនដែលមានប្រភពនៅក្នុងសួនច្បារអេដែន (ហើយគេបានបន្តឃើញការ រុករកឃើញខាងវត្ថុបុរាណគួរឲ្យភ្ញាក់ផ្អើលអំពីទន្លេទាំងនេះ)។ លោកុប្បត្តិ ២:១៥ សរសេរថា "ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បានយកអ័ដាមទៅដាក់នៅក្នុងសួនច្បារអេដែនឲ្យគាត់ធ្វើការហើយថែរក្សា"។ កិរិយាស័ព្ទភាសាហេព្រើរ "ធ្វើការ" និង "ថែរក្សា" គឺជាពាក្យសាមញ្ញណាស់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ហើយអត្ថន័យឫសរបស់ពាក្យទាំងពីរនេះគឺ "បំរើ" និង"ការពារ"។ អ័ដាមត្រូវតែបំរើសួនច្បារអេដែនដោយកម្លាំងពលកម្មរបស់ខ្លួន ធ្វើការតាមអ្វីដែលទ្រង់បង្ហាត់បង្រៀនឱ្យគាត់ចេះធ្វើដីដើម្បីអោយនាំសួនច្បារនេះឈានដល់សក្តានុពលពេញលេញរបស់វា។ តិណជាតិនិងដំណាំកសិកម្មផ្សេងៗទៀតដែលត្រូវបានលើកឡើងក្នុងលោកុប្បត្តិ ២:៥ នឹងទទួលបានការថែរក្សាដែលពួកវាត្រូវការដើម្បីលូតលាស់។ សេចក្តីបង្គាប់ទីពីរគឺ ការពារកំណត់សេចក្តីថាគ្រោះដែលនឹងកើតមានបានគំរាមកំហែងសោភ័ណភាព និងសន្តិភាពរបស់សួនច្បារអេដែន។ គ្រោះថ្នាក់នេះត្រូវបានបើកសំដែងនៅក្នុងលោកុប្បត្តិ ៣ ដែលសាតាំងមកក្នុងទំរង់ជាសត្វពស់ដើម្បីល្បួងអេវ៉ា និងអ័ដាម ហើយនាំពួកគេ (ហើយនិងសួនច្បារអេដែន) ទៅក្នុងសេចក្តីស្លាប់។

ដែលបានដាក់អ័ដាមនៅក្នុងសួនច្បារអេដែន នោះព្រះបានប្រទានសេចក្តីបង្គាប់ច្បាស់លាស់នេះដល់គាត់ "ឯងនឹងស៊ីផ្លែឈើទាំងអស់ក្នុងសួនច្បារនេះបានតាមចិត្ត តែឯត្រង់ដើមដឹងខុសត្រូវ នោះមិនត្រូវឲ្យឯងស៊ីផលឡើយ ដ្បិតនៅថ្ងៃណាដែលឯងស៊ី នោះនឹងត្រូវស្លាប់ជាមិនខាន" (លោកុប្បត្តិ ២:១៦-១៧)។ នៅទីនេះព្រះបានដាក់អ័ដាមនៅក្រោមការហាមប្រាមមួយ។ នេះគឺជាក្រឹត្យវិន័យ ការព្រមាន និងដែនកំណត់។ អ័ដាមត្រូវបានប្រគល់ឲ្យគ្រប់គ្រងផែនដីទាំងមូល ប៉ុន្តែអ័ដាមខ្លួនគាត់ផ្ទាល់ត្រូវតែចុះចូលចំពោះព្រះ។

## *ការបង្កើតអេវ៉ា និងអាពាហ៍ពិពាហ៍*

ព្រះបានបង្កើតមនុស្សប្រុសស្រីដូចជារូបអង្គទ្រង់ ហើយបង្គាប់ឲ្យពួកគេចំរើនឡើង បង្កើតកូនចៅឲ្យពេញផែនដី (លោកុប្បត្តិ ១:២៦-២៧)។ ប៉ុន្តែពេលដំបូងអ័ដាមត្រូវបានបង្កើតមកតែម្នាក់ឯង រស់នៅតែម្នាក់ឯង។ ទោះបើព្រះបានប្រកាសថា វាមិនជាការល្អសំរាប់អ័ដាមនៅម្នាក់ឯងក៏ដោយ ក៏ព្រះបានបង្កើតគាត់ជាដំបូងដោយចេតនាហើយទុកឲ្យគាត់រស់នៅម្នាក់ឯងអស់មួយរយៈខ្លីនោះឡើយ។ ព្រះធ្វើការនេះដើម្បីយកអ័ដាមធ្វើជាក្បាលរបស់ប្រពន្ធរបស់គាត់ ហើយដើម្បីបង្ហាញតួនាទីរបស់នាងជា "អ្នកជំនួយដែលសមនឹងគាត់"(លោកុប្បត្តិ ២:១៨, សូមមើល១កូរិនថូស ១១:២-១៦, អេភេសូរ ៥:២២-៣៣, ១ធីម៉ូថេ ២:១១-១៥)។

បន្ទាប់ពីអ័ដាមដាក់ឈ្មោះឲ្យសត្វ (លោកុប្បត្តិ ២:១៩-២០) វាច្បាស់លាស់ថាក្នុងចំណោមពួកសត្វទាំងនេះមិនមានអ្នកជំនួយណាសមនឹងគាត់នោះទេ។ អ័ដាមមិនអាចបង្កើតកូនចៅដោយម្នាក់ឯងនោះបានទេ ឬក៏មិនអាចស្រលាញ់ឬទាក់ទងនឹងម្នាក់ណាទៀតដែលជាអ្នកដែលព្រះបានបង្កើតឲ្យមានរូបភាពនៃព្រះបានដែរ។ ដូច្នេះ ព្រះបានបណ្តាលអ័ដាមឲ្យគាត់ដេកលក់ ហើយទ្រង់បានយកឆ្អឹងជំនីមួយរបស់អ័ដាមដើម្បីបង្កើតជាមនុស្សស្រីម្នាក់នៅពេលគាត់កំពុងដេកលក់។ ព្រះបានប្រគល់នាងទៅឲ្យអ័ដាមធ្វើជាប្រពន្ធរបស់គាត់។ អ័ដាមមានអំណរ និងនិយាយជាពាក្យកំណាព្យថា "នេះហើយជាឆ្អឹងពីឆ្អឹងអញ ជាសាច់ពីសាច់អញ នឹងត្រូវហៅថា "ស្ត្រី" ពីព្រោះបានយកចេញពីបុរសមក" (ខ. ២៣)"។

តាមរយៈការដាក់ឈ្មោះឲ្យនាង អ័ដាមបង្ហាញអំណាចរបស់គាត់នៅក្នុងអាពាហ៍ពិពាហ៍ ប៉ុន្តែនៅក្នុងការអបអរសាទររបស់គាត់ពីព្រោះនាងមានខ្លឹមសារដូចគ្នានឹងគាត់ គាត់បង្ហាញភាពជាដៃគូដែលពួកគេត្រូវបានបង្កើតមកដោយភាពស្មើគ្នានៅក្នុងរូបភាពនៃព្រះ។ នេះគឺជាដើមកំណើតនៃអាពាហ៍ពិពាហ៍ដែលជាទំនាក់ទំនងរបស់មនុស្សដំបូងនៅក្នុងព្រះគម្ពីរ ហើយជាគំរូសំរាប់អាពាហ៍ពិពាហ៍ក្នុងពេលអនាគត។ វាក៏ជារូបភាពនៃព្រះគ្រីស្ទ និងពួកជំនុំផងដែរ (អេភេសូរ ៥:៣២)។

មុនពេលពួកគេបានធ្វើបាបទាស់នឹងព្រះ ពួកគេមានសេរីភាពដែលពួកគេ "ទាំងពីរនៅអាក្រាតទទេ ឥតមានសេចក្តីខ្មាសអៀនឡើយ" (លោកុប្បត្តិ ២:២៥) ក៏គ្មានអ្វីលាក់លៀមគ្នាដែរ គឺខុសគ្នាខ្លាំងណាស់ពីស្ថានភាពអាក្រក់បន្ទាប់ពីអំពើបាបបានមានជ័យជំនះលើពួកគេ។

## *ការធ្លាក់ចុះដែលវិនាសមួយចំពោះការបង្កបង្កើត*

ពិភពលោកដែលនៅជុំវិញយើងគឺខុសគ្នាខ្លាំងណាស់ពីពិភពលោកឥតខ្ចោះដែលបាននៅជុំវិញអ័ដាម និងអេវ៉ានៅក្នុងសួនច្បារអេដែន។ អ័ដាមដែលតំណាងឲ្យមនុស្សជាតិបានបរាជ័យក្នុងការបំរើ និងការពារប្រពន្ធរបស់គាត់នៅក្នុងសួនច្បារអេដែន។ គាត់បានឈរនៅក្បែរយ៉ាងឥតបានការនៅពេលសាតាំងបានល្បួងប្រពន្ធ ហើយបន្ទាប់មកគាត់ក៏តាមនាងធ្លាក់ចូលទៅក្នុងការបះបោរជំហរដោយការស៊ីផ្លែរបស់ដើមដឹងខុសត្រូវ (លោកុប្បត្តិ ៣:១-៧)។

ព្រះបានយាងមកធ្វើអ្នកវិនិច្ឆ័យលើផែនដីទាំងមូលហើយដំបូងប្រឈមនឹងអ័ដាម បន្ទាប់មកអេវ៉ា និងបន្ទាប់មកសត្វពស់។ ទ្រង់ដាក់បណ្តាសាអ្នកទាំងបីតាមវេន ហើយបណ្តាសារបស់អ័ដាមផ្ទាល់គឺជាបណ្តាសារបស់ផែនដីដែរ "នោះដីត្រូវបណ្តាសាដោយព្រោះឯង ឯងត្រូវរកស៊ីពីដីដោយនឿយហត់អស់មួយជីវិត ដីនឹងដុះជាបន្លាហើយនិងអញ្ចាញឲ្យឯង ឯងត្រូវស៊ីអស់ទាំងតិណជាតិនៅស្រែចំការ" (លោកុប្បត្តិ ៣:១៧-១៨)។

ចាប់ពីពេលនោះមក របស់សព្វសារពើដែលព្រះបានបង្កើតបានយំថ្ងូរនៅក្នុងចំណងពុករលួយនិងឥតន័យ ទន្ទឹងចង់បានការបំពេញសេចក្តីសង្គ្រោះដែលមានសិរីល្អរបស់មនុស្សជាតិ (រ៉ូម ៨:១៨-២២)។ យើងមើលឃើញភស្តុតាងនៃការយំថ្ងូរ ការជាប់ចំណង ភាពពុករលួយ និងភាពឥតន័យជារៀងរាល់ថ្ងៃ ហើយយើងផ្ទាល់ទន្ទឹងចង់បានថ្ងៃមួយដែលរបស់សព្វសារពើដែលព្រះបានបង្កើតនឹងមានសេរីភាព ឥតខ្ចោះ និងមានសិរីល្អម្តងទៀត។

## *ផែនដីថ្មីនិងស្ថានសួគ៌ថ្មី*

ដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទគឺជាអំណាចព្រះចេស្តានាំផែនដីថ្មីនិងស្ថានសួគ៌ថ្មីនោះមកដល់។ សម័យថ្មីក្នុងប្រវត្តិសាស្ត្រមនុស្សជាតិបានចាប់ផ្តើមដោយការរស់ពីសុគតឡើងវិញរបស់ព្រះគ្រីស្ទ។ រូបកាយរស់ពីសុគតរបស់ព្រះគ្រីស្ទ "រូបកាយខាងព្រលឹងវិញ្ញាណ" គឺជាគំរូដើមសំរាប់សកលលោកថ្មីមួយ។ ទ្រង់ជាផលដំបូងពីពួកអ្នកស្លាប់ (១កូរិនថូស ១៥:២០, ២៣)។ ដោយសារតែដំណឹងល្អអំពីការសុគតរបស់ព្រះគ្រីស្ទដែលប្រោសលោះយើងហើយការរស់ឡើងវិញដែលពេញដោយសិរីល្អរីកផ្សាយទូទាំងពិភពលោក នោះពូជពង្សដែលមានបាបរបស់អ័ដាមកំពុងប្រែចិត្ត និងជឿលើព្រះគ្រីស្ទ ហើយពួកគេរកឃើញសេចក្តីប្រោសលោះនៅក្នុងទ្រង់។ នៅពេលពួកគេទទួលយកព្រះគ្រីស្ទ នោះពួកគេត្រូវបាន "កើតជាថ្មី" (២កូរិនថូស ៥:១៧) ហើយពួកគេទន្ទឹងចង់បានការកើតជាថ្មីខាងសាច់ឈាមផងដែរ។

ដូច្នេះ ទាំងគ្រីស្ទបរិស័ទ និងសកលលោកទាំងមូលក៏ស្រែកថ្ងូរពីខាងក្នុងនៅពេលយើងរង់ចាំសេចក្តីប្រោសលោះចុងក្រោយរបស់យើងយ៉ាងឆេះឆួលដែលជាការរស់ឡើងវិញរបស់រូបកាយរបស់យើង (រ៉ូម ៨:២៣)។ នៅពេលព្រះគ្រីស្ទយាងមកជាលើកទីពីរ សេចក្តីសង្ឃឹមយ៉ាងក្លៀវក្លានេះនឹងត្រូវបានបំពេញសំរេច ហើយការបង្កបង្កើតផ្ទាល់នឹងត្រូវបានបង្កើតជាថ្មី។ សកលលោកខាងព្រលឹងវិញ្ញាណនិងសាច់ឈាមនឹងត្រូវបានរស់ឡើងវិញ ដូចជារូបកាយរបស់យើង ដូច្នេះនឹងមានដំណើរបន្តនិងភាពខុសគ្នា។ ហើយសកលលោកថ្មីនោះមានឈ្មោះដែលពេញដោយសិរីល្អថា "ផ្ទៃមេឃថ្មីនិងផែនដីថ្មីដែលមានសុទ្ធតែសេចក្តីសុចរិតវិញ" (២ពេត្រុស ៣:១៣)។

## *ការអនុវត្តដែលមកពីសេចក្តីពិតដែលថា ព្រះជាម្ចាស់បានបង្កើតរបស់សព្វសារពើ*

សេចក្តីពិតដែលថា ព្រះជាម្ចាស់បានបង្កើតរបស់សព្វសារពើគួរតែបើកភ្នែករបស់យើងឲ្យមើលឃើញសិរីល្អរបស់ព្រះដែលនៅជុំវិញយើង ហើយគួរតែធ្វើឲ្យយើងអាចមានហេតុផលច្រើនរាប់មិនអស់ក្នុងការសរសើរតម្កើង និងថ្វាយបង្គំដល់

ព្រះ។ យើងគួរតែថ្វាយការអរគុណដល់ព្រះសំរាប់សោភណភាពផែនដី សំរាប់ការបង្ហាញរបស់វាអំពីសេចក្ដីល្អនិងសេចក្ដីស្រលាញ់របស់ទ្រង់ សំរាប់ប្រភេទផ្សេងៗគ្នាដែលមានលើផែនដី ហើយវាផ្តល់សេចក្តីត្រូវការដល់យើង បើទោះវាមានបណ្តាសាក៏ដោយ។

មិនត្រឹមតែរបស់សព្វសារពើដែលព្រះបានបង្កើតបង្ហាញអំពីអំណាចរបស់ព្រះដ៏ជាព្រះអាទិករប៉ុណ្ណោះទេ ប៉ុន្តែដូចជាដាវីឌនៅក្នុងទំនុកដំកើង ១៣៩ យើងគួរតែស្ញើចសរសើរដែលព្រះបានបង្កើតយើងដោយផ្ទាល់នៅក្នុងផ្ទៃម្តាយរបស់យើង ហើយទ្រទ្រង់យើងគ្រប់ពេលវេលានៃជីវិតរបស់យើង។ យើងគួរតែយល់ថាក្នុងព្រះ "យើងរាល់គ្នាបានរស់កំរើក ហើយមាននៅផង" (កិច្ចការ ១៧:២៨)។ យើងគួរតែដឹងថាព្រះកាន់ជីវិតនិងផ្លូវទាំងអស់របស់យើងនៅក្នុងព្រះហស្តរបស់ទ្រង់ (ដានីយ៉ែល ៥:២៣)។ ការនេះគួរជំរុញយើងឲ្យមានភាពជិតស្និទ្ធដែលភ័យរន្ធត់ជាមួយព្រះដែលដាវីឌបង្ហាញនៅក្នុងទំនុកដំកើង ១៣៩ ថា "ឱព្រះអង្គអើយ សូមពិនិត្យមើលឲ្យបានស្គាល់ចិត្តទូលបង្គំផង" (ខ. ២៣)។

ការកើតជាថ្មីរបស់យើងគឺដូចជាអ្វីដែលព្រះបានធ្វើកាលពីការចាប់ផ្តើមការបង្កបង្កើតដែរ "ដ្បិតគឺជាព្រះដែលមានបន្ទូលបង្គាប់ ឲ្យមានពន្លឺភ្លឺចេញពីសេចក្តីងងឹត ទ្រង់បានបំភ្លឺមកក្នុងចិត្តយើងខ្ញុំ ឲ្យយើងខ្ញុំមានរស្មីពន្លឺនៃដំណើរស្គាល់សិរីល្អរបស់ព្រះ ដែលនៅព្រះភក្ត្រនៃព្រះយេស៊ូវគ្រីស្ទ" (២កូរិនថូស ៤:៦)។ ការនេះបង្ហាញយ៉ាងច្បាស់អំពីអធិបតីភាពទាំងស្រុងរបស់ព្រះនៅក្នុងការប្រែចិត្តជឿរបស់យើង។ ដូចដែលព្រះបានមានបន្ទូលនៅការបង្កបង្កើតនៅពេលវានៅងងឹតថា "ចូរឲ្យមានពន្លឺ" នោះក៏មានពន្លឺ ដូច្នេះព្រះក៏បានមានបន្ទូលទៅក្នុងភាពងងឹតរបស់ចិត្តយើងដើម្បីបង្កើតពន្លឺខាងវិញ្ញាណថ្មីមួយដែលជាពន្លឺរបស់ព្រះគ្រីស្ទ។ នេះជា អត្ថន័យនៃការកើតជាថ្មី ហើយមានតែព្រះទេដែលមានអធិបតីភាពអាចធ្វើការនេះបាន។ ហើយនៅពេលព្រះសព្វព្រះទ័យធ្វើការនេះ នោះគ្មានអំណាចណាក្នុងសកលលោកអាចបញ្ឈប់ទ្រង់បានឡើយ!

ការបង្កបង្កើតគឺជាកន្លែងចាប់ផ្តើមដែលសាមញ្ញនិងច្បាស់លាស់បំផុតសំរាប់ឪពុកម្តាយបង្រៀនកូនចៅរបស់ពួកគេអំពីការគង់នៅ និងលក្ខណៈសម្បត្តិរបស់ព្រះ។ ឪពុកម្តាយគួរសរសើរតម្កើង និងអរព្រះគុណព្រះដ៏ជាព្រះអាទិករដោយពាក្យសម្តីយ៉ាងខ្ជាប់ខ្ជួន ហើយបន្ទាប់មកស្វែងរកភាពស្រដៀងគ្នាខាងព្រលឹងវិញ្ញាណទាំងនោះដែលបានលើកឡើងនៅក្នុងចំនុចមុននេះដើម្បីបង្រៀនកូនចៅរបស់ពួកគេអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ។

កណ្ឌជាច្រើនក្នុងព្រះគម្ពីរចាប់ផ្តើមការបង្ហាញអំពីសេចក្តីពិតដំណឹងល្អដោយគោលលទ្ធិនៃការបង្កបង្កើត (ឧទាហរណ៍ដូចជា លោកុប្បត្តិ យ៉ូហាន រ៉ូម កូល៉ុស ហេព្រើរ)។ នេះគឺជាចំនុចទំនាក់ទំនងមួយដែលយើងអាចមានជាមួយលោកិយដែលមិនស្គាល់ព្រះគម្ពីរបាន។ នៅពេលយើងនាំដំណឹងល្អទៅកាន់ចុងបំផុតនៃផែនដីដើម្បីទៅកាន់ក្រុមមនុស្សដែលដំណឹងល្អមិនទាន់ទៅដល់ នោះចំនុចចាប់ផ្តើមនៃការប្រកាសរបស់យើងនឹងជាការបង្កបង្កើត ។ ការនេះកាន់តែពិតនៅក្នុងលោកខាងលិច នៅពេលមនុស្សកាន់តិចទៅៗក្នុងលោកខាងលិចស្គាល់ព្រះគម្ពីរ។ ព្រះរាជសារដំណឹងល្អផ្ទាល់ ក៏គួរតែភ្ជាប់យ៉ាងជិតស្និទ្ធជាមួយការបង្កបង្កើតផងដែរ។

ព្រះអាទិករបានប្រគល់ឲ្យយើងគ្រប់គ្រងលើផែនដី ដូច្នេះហើយយើងគ្រាន់តែជាអ្នកកាប់រងទ្រព្យសម្បត្តិរបស់ម្នាក់ទៀត (គឺព្រះអាទិករ)ប៉ុណ្ណោះ។ យើងគួរតែចាត់ទុកផែនដីជាស្នាព្រះហស្តរបស់ព្រះវរបិតានៃស្ថានសួគ៌របស់យើងហើយថែរក្សាវាដោយក្តីស្រលាញ់។ យើងគួរតែបំរើ និងការពារផែនដី នាំវាទៅដល់សក្តានុពលពេញលេញរបស់វានៅក្រោមព្រះ ដោយមិនថ្វាយបង្គំស្នាព្រះហស្តនោះឡើយ។

គ្រីស្ទបរិស័ទទាំងអស់ដែលមានការត្រាស់ហៅឲ្យសិក្សាវិទ្យាសាស្ត្រ គួរតែធ្វើដូច្នោះក្នុងនាមជាអ្នកថ្វាយបង្គំព្រះជាម្ចាស់។ ពួកអ្នកវិទ្យាសាស្ត្រគួរតែមើលឃើញការងាររបស់ពួកគេជាការលាតត្រដាងការអស្ចារ្យរបស់ព្រះដ៏ជាព្រះអាទិករ ហើយបន្ទាប់មកពន្យល់សេចក្តីពិតអស្ចារ្យទាំងនោះដល់បងប្អូនប្រុសស្រីក្នុងព្រះគ្រីស្ទសំរាប់គោលបំណងថ្វាយបង្គំ និងសំរាប់ផលប្រយោជន៍មនុស្សជាតិ។ ពួកអ្នកវិទ្យាសាស្ត្រមិនគួរបញ្ឈប់ការប្តេជ្ញាចំពោះសេចក្តីពិតរបស់ព្រះគម្ពីរទេ នៅពេលពួកគេរកឃើញសេចក្តីពិតថ្មីៗនៅក្នុងសកលលោកដែលព្រះបានបង្កើត។

ព្រះគម្ពីរ គឺជាការបើកសំដែងដ៏អស្ចារ្យ និងច្បាស់លាស់បំផុតអំពីគំនិតរបស់ព្រះចំពោះមនុស្សជាតិ ប៉ុន្តែព្រះគម្ពីរផ្ទាល់មិនអាចត្រូវបានយល់ក្រៅពីស្មាព្រះហស្តនៅជុំវិញយើងបាននោះឡើយ។ ព្រះគម្ពីរនិយាយមកកាន់យើងជាភាសារបស់ពិភពលោកនេះ ប្រើសេចក្តីស្រដៀងគ្នាដែលមើលឃើញនៅក្នុងផែនដី និងសកលលោកដើម្បីបង្រៀនយើងអំពីសេចក្តីពិតខាងវិញ្ញាណ។ ព្រះយេស៊ូវធ្វើការនេះរាល់ពេលហើយពីដំណើរសម្លៀកបំពាក់ តើអ្នករាល់គ្នាខំខ្វល់ខ្វាយធ្វើអី? ចូររំពឹងគិតតែពីផ្កាឈូកនៅក្នុងបឹង ដែលវាដុះជាយ៉ាងដូចម្តេច គឺវាមិននឿយហត់នឹងធ្វើការ ឬស្រាវរវៃទេ (ម៉ាថាយ ៦:២៨) ឯខ្យល់ ចង់បក់ទៅឯណា ក៏ចេះតែបាន ហើយអ្នកឮសូរសព្ទ តែមិនដឹងជាមកពីណា ឬទៅឯណាទេ អស់អ្នកណាដែលកើតមក ពីព្រះវិញ្ញាណ នោះក៏ដូច្នោះដែរ (យ៉ូហាន ៣:៨) ទ្រង់មានបន្ទូលពាក្យប្រៀបប្រដូចនេះ អោយគេទៀត ថា នគរស្ថានសួគ៌ប្រៀបដូចជាដំបែ ដែលស្ត្រីម្នាក់បានយក មកលាយនឹងម្សៅ៣រង្វាល់១ ទាល់តែម្សៅនោះបានដោរឡើងគ្រប់ទាំងអស់ (ម៉ាថាយ ១៣:៣៣)។

ដោយសារយើងឆ្លងកាត់ជីវិតក្នុងពិភពលោកដែលត្រូវបណ្តាសាដោយអំពើបាបនេះ នោះយើងអាចងាយនឹងនឿយហត់ និងបាក់ទឹកចិត្ត។ ទំនុកដំកើង ២៣ និយាយថា " ទ្រង់កែព្រលឹងខ្ញុំឡើងវិញ" (ខ. ៣)។ ជារឿយៗព្រះធ្វើដូច្នេះដោយស្នាព្រះហស្តរបស់ទ្រង់ដែលមានអំណាចកែយើងជាថ្មីវិញ។ ចូរយកការទស្សនាធម្មជាតិជាផ្នែកមួយនៃការដើរជាមួយព្រះគ្រីស្ទរបស់អ្នក។ ចូរទៅឆ្នេរសមុទ្រហើយមើលសមុទ្រដ៏ធំ។ ចូរឡើងភ្នំហើយមើលសត្វតន្ទ្រីហើរសំកាំងខ្ពស់ពីខ្យល់អាកាសដ៏កក់ក្តៅ។ ចូរស្ញើចសរសើរដែលមានភ្នំនិងជ្រលងភ្នំធំៗ។ ចូរអនុញ្ញាតឲ្យស្នាព្រះហស្តកែព្រលឹងរបស់អ្នកជាថ្មីឡើង។

រ៉ូម ៨ និយាយថាសេចក្តីសង្ឃឹមរបស់គ្រីស្ទបរិស័ទម្នាក់គឺនៅក្នុងការរស់ឡើងវិញខាងរូបកាយ និងសកលលោកផងដែរ។ ចូររស់ដោយសេចក្តីសង្ឃឹមមុតមាំឲ្យបានផែនដីថ្មី និងស្ថានសួគ៌ថ្មីដែលនឹងមកដល់។ ចូរឆេះឆួលជាមួយវា អធិស្ឋានឲ្យបានវា ហើយនិងផ្សាយដំណឹងល្អដល់ពួកអ្នកបាត់បង់ដើម្បីរៀបចំការមកដល់របស់វា។

## កំណត់

១. ខគម្ពីរយោងដែលត្រូវបានដកស្រង់ចេញពីព្រះគម្ពីរខ្មែរបរិសុទ្ធ (១៩៥៤)។

២. Richard Dawkins, The Blind Watchmaker (New York: Norton, 1991), 1.